**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

**សំណុំរឿងលេខ៖** ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ត.ក

**ភាគីដាក់ឯកសារ៖** ក្រុមមេធាវីការពារក្តី នួន ជា

**ដាក់ជូន៖** អង្គជំនុំជម្រះតុលាការកំពូល

**ភាសាដើម៖** អង់គ្លេស

**កាលបរិច្ឆេទឯកសារ៖** ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៥

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 07-Sep-2015, 13:45
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

**ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖** សាធារណៈ

**ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាតុលាការកំពូល៖** សាធារណៈ/Public

**ចំណាត់ថ្នាក់ប្រភេទឯកសារ៖**

**ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន៖**

**ឈ្មោះមន្ត្រីកត់ត្រា៖**

**ហត្ថលេខា៖**

---

# សំណើសុំឲ្យបំពេញកិច្ចស៊ើបសួរនៅលើព្រឹត្តិការណ៍នានាដែលពិពណ៌នានៅក្នុងអំឡុងពេលនៃការផ្តល់សក្ខីកម្មរបស់ សំ សិទ្ធី

---

**ដាក់ដោយ÷**

**ក្រុមមេធាវីការពារក្តី នួន ជា**

សុន អរុណ
Victor KOPPE
លីវ សុវណ្ណា
ព្រុំ ផល្លា
Doreen CHEN
Xiaoyang NIE
Marina HAKKOU
Henri DECOEUR

**ចម្លងជូន÷**

**សហមេធាវីការពារក្តី ខៀវ សំផន÷**

គង់ សំអុន
Anta GUISSÉ
Arthur VERCKEN

**សហព្រះរាជអាជ្ញា÷**

ជា លាង
Nicholas KOUMJIAN

០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

<u>**សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី**</u>

**ពេជ អង្គ**

Marie GUIRAUD

# I. សេចក្តីផ្តើម

1. នៅថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤ សហមេធាវីរបស់ នួន ជា ("មេធាវីការពារក្តី") បានដាក់បណ្តឹងសាទុក្ខរបស់ នួន ជា ("បណ្តឹងសាទុក្ខ")[1] ប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១ ("សាលក្រម")[2]។ មេធាវីការពារក្តីបានជំទាស់ *ក្នុងចំណោមប្រការផ្សេងទៀត* ថា៖ សហចៅក្រមស៊ើបអង្កេត ("ស.ច.ស") បានដាក់កម្រិតដែលមិនធ្លាប់មានពីមុនមក និងដោយខុសច្បាប់ទៅលើលទ្ធភាពរបស់ នួន ជា ក្នុងការសួរដេញដោលលើភ័ស្តុតាងប្រឆាំងនឹងរូបគាត់ និងជំរុញរឿងក្តីរបស់គាត់ក្នុងអំឡុងពេលនៃការស៊ើបអង្កេត[3]ថា អង្គជំនុំជម្រះសាលាដំបូងបានបន្តរារាំងការខិតខំប្រឹងប្រែងរបស់មេធាវីការពារក្តី ក្នុងការសួរដេញដោលលើភ័ស្តុតាងដែលបានប្រមូលបានដោយ ស.ច.ស *ក្នុងចំណោមប្រការផ្សេងទៀត* ដោយអនុញ្ញាតឲ្យសាក្សីពិនិត្យមើលឡើងវិញលើចម្លើយរបស់ពួកគេ មុនពេលផ្តល់សក្ខីកម្ម[4], ថា អង្គជំនុំជម្រះសាលាដំបូងក្រោយមកទៀតបានផ្អែកយ៉ាងច្រើនទៅលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងចម្លើយដទៃទៀតដែលទទួលបាននៅក្រៅក្របខ័ណ្ឌតុលាការ ដោយ (ទីមួយ) មិនបានធ្វើការពិចារណាឲ្យបានត្រឹមត្រូវជាបឋមទៅលើភ័ស្តុតាងដែលផ្តល់ជូនដោយផ្ទាល់ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និង (ទីពីរ) ស.ច.ស នោះឡើយ[5], ថា ភ័ស្តុតាងផ្ទាល់អំពីគោលនយោបាយរបស់ ប.ក.ក ពាក់ព័ន្ធនឹងទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ មានតិចតួចបំផុត ហើយជារួមគឺជាភ័ស្តុតាងដោះបន្ទុក[6] និងថាភ័ស្តុតាងដែលថា ទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរត្រូវបានកំណត់គោលដៅក្នុងការសម្លាប់នោះ គឺជារឿងរ៉ាវផ្ទាល់ខ្លួន មិនគួរឲ្យជឿជាក់បាន និងរួមមានចម្លើយដែលទទួលបាននៅក្រៅក្របខ័ណ្ឌតុលាការ និងសក្ខីកម្មចចាមអារ៉ាម<u>ទាំងស្រុង</u>[7]។ មេធាវីការពារក្តីបានជំទាស់បន្ថែមទៀតថា ភ័ស្តុតាងមួយក្នុងចំណោម ចម្លើយដែលទទួលបាននៅក្រៅក្របខ័ណ្ឌតុលាការទាំងនេះ

---

[1] ឯកសារ **F16** "បណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសាលក្រម ក្នុងសំណុំរឿង ០០២/០១" ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤ ("បណ្តឹងសាទុក្ខ")។

[2] ឯកសារ **E313** "សាលក្រម សំណុំរឿង ០០២/០១") ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤។

[3] បណ្តឹងសាទុក្ខ កថាខណ្ឌ ៣១-៣២, ១៣៣-១៣៤។

[4] *ដូចយោងខាងលើ* កថាខណ្ឌ ១៣៥-១៤៧។

[5] *ដូចយោងខាងលើ* កថាខណ្ឌ ១៥៤-១៧១។

[6] *ដូចយោងខាងលើ* កថាខណ្ឌ ៥៥១-៥៨០។

[7] *ដូចយោងខាងលើ* កថាខណ្ឌ ៥៨១-៥៩៦។

ពោលគឺកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ សិទ្ធី ពុំមាននៅក្នុងកំណត់ហេតុ ដែលចម្លើយនេះមានបំណងផ្តល់សក្ខីកម្មជាសាក្សីឃើញផ្ទាល់ភ្នែកអំពីទាហានរបបសាធារណរដ្ឋខ្មែរដែលត្រូវបានចាប់ខ្លួន នាំខ្លួនយកទៅបាត់ ហើយបន្ទាប់មកត្រូវបានសម្លាប់ចោលដោយកងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជា ក្នុងអំឡុងនៃការជម្លៀសចេញពីទីក្រុងនានា។ ដូច្នេះ មេធាវីការពារក្តីស្នើសុំឱ្យអង្គជំនុំជម្រះកោះហៅ សំ សិទ្ធី ឱ្យចូលខ្លួនមកផ្តល់សក្ខីកម្ម[8]។ នៅថ្ងៃទី ២៩ ខែឧសភា ឆ្នាំ ២០១៥ អង្គជំនុំជម្រះនេះបានយល់ស្របតាមសំណើនោះ[9]។

2. នៅថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០១៥ សំ សិទ្ធី បានបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះនេះ។ សំ សិទ្ធី បានផ្តល់សក្ខីកម្មដែលមានលក្ខណៈមិនស៊ីសង្វាក់គ្នាខ្លាំង ខុសគ្នាពីភស្តុតាងនៅក្នុងកំណត់ហេតុនៃការស្តាប់ចម្លើយរបស់គាត់ និងផ្ទុយទៅនឹងភស្តុតាងដទៃទៀតនៅក្នុងសំណុំរឿង។ គាត់មិនបានកំណត់ឈ្មោះជនរងគ្រោះណាម្នាក់ឡើយ ក្រៅតែពីឪពុកម្តាយរបស់គាត់ ទោះបីជាគាត់អះអាងថា សាច់ញាតិជាច្រើន រួមមាន ម្តាយមីង ឪពុកមា និងបងប្អូនជីដូនមួយ ត្រូវបានសម្លាប់យ៉ាងណាក៏ដោយ។ ទោះបីជាគាត់ជាមន្ត្រីនគរបាលជាន់ខ្ពស់ម្នាក់ នៅក្នុងខេត្តតែមួយនោះដែលមានការចោទប្រកាន់ថា ការកាប់សម្លាប់បានកើតឡើងយ៉ាងណាក៏ដោយ ពោលគឺគាត់ជាអធិការក្រុងកំពង់ឆ្នាំងក៏ដោយ ក៏គាត់មិនធ្លាប់បានដឹងអំពីការព្យាយាមជីករណ្តៅសាកសពនៅក្នុងពេលណាមួយចាប់តាំងពីឆ្នាំ ១៩៧៩ មកនោះឡើយ រួមទាំងរណ្តៅសាកសពរួម (ដែលគេស្គាល់យ៉ាងច្បាស់ថាជារណ្តៅគ្រាប់ បេ-៥២) ដែលក្រុមគ្រួសាររបស់គាត់ត្រូវបានសន្និដ្ឋានថាកប់នៅទីនោះ។ អ្វីដែលនៅមាននៅក្នុងកំណត់ហេតុ គឺជាការរៀបរាប់ដែលមិនមានការបញ្ជាក់អះអាងទាល់តែសោះ ដែលខ្វះនូវព័ត៌មានលម្អិតសំខាន់ជាច្រើន និងមិនស៊ីសង្វាក់គ្នានៅក្នុងផ្នែកសំខាន់ៗជាមួយនឹងភស្តុតាងដទៃទៀតនៅក្នុងសំណុំរឿង រួមទាំងចម្លើយពីមុនរបស់ សំ សិទ្ធី ផ្ទាល់តែម្តង។

3. ផ្អែកតាមកាលៈទេសៈទាំងនេះ កិច្ចស៊ើបសួរបន្ថែមទៀត គឺមានសារៈសំខាន់ជាចាំបាច់ ដើម្បីជាមធ្យោបាយមួយក្នុងការវាយតម្លៃទៅលើភាពគួរឱ្យជឿជាក់បាននៃសក្ខីកម្មរបស់ សំ សិទ្ធី។ កិច្ចខិតខំប្រឹងប្រែងដ៏សាមញ្ញដើម្បីទទួលបាននូវភស្តុតាងដែលស៊ីសង្វាក់គ្នា ដែលបានស្នើសុំនៅក្នុងសំណើនេះ ពោលគឺស្វែងរកទីតាំងរណ្តៅសាកសព និងភស្តុតាងរូបវន្តដទៃទៀត និងស្តាប់ចម្លើយសាក្សី

---

[8] *ដូចយោងខាងលើ* កថាខណ្ឌ ៥៩៥, ៧៣០(គ)។

[9] ឯកសារ **F2/5** "សេចក្តីសម្រេចលើផ្នែកខ្លះនៃសំណើរបស់ នួន ជា សុំកោះហៅសាក្សីលើបណ្តឹងសាទុក្ខ" ថ្ងៃទី ២៩ ខែឧសភា ឆ្នាំ ២០១៥ ("សេចក្តីសម្រេចលើសំណើរបស់ នួន ជា សុំកោះហៅសាក្សី")។

សំខាន់ៗ និងការស្វែងរកអត្ថបទដែល សំ សិទ្ធី សម្ភាសនៅក្នុងការសែត គឺមានសារៈសំខាន់ណាស់ចំពោះការវាយតម្លៃអំពីតម្លៃជាភ័ស្តុតាង និងជាមូលដ្ឋានចំពោះរាល់កិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ។ ការខកខានរបស់ ស.ច.ស និងក្រោយមកទៀត ការខកខានរបស់អង្គជំនុំជម្រះសាលាដំបូងមិនបានបង្ហាញភ័ស្តុតាងបែបនេះ គឺមិនជាប់ពាក់ព័ន្ធទាល់តែសោះទៅនឹងកង្វះវិរិយភាពរបស់ នួន ជា។ ឋានៈរបស់ សំ សិទ្ធី ដែលជាសាក្សីឃើញផ្ទាល់ភ្នែកតែម្នាក់គត់នៅក្នុងសំណុំរឿងនេះ ចំពោះការអនុវត្តមួយដែលអង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា មានលក្ខណៈទូទៅនៅក្នុងរយៈកាលក្រោយពីរំដោះនោះ តម្រូវថា ភ័ស្តុតាងរបស់គាត់ត្រូវមានការពិនិត្យពិច័យឲ្យបានហ្មត់ចត់ ដែលនៅក្នុងសាលក្រម ពុំមានការពិនិត្យពិច័យបែបនេះទាល់តែសោះ។

## II. សក្ខីកម្មរបស់ សំ សិទ្ធី

4. កំណត់ហេតុនៃការស្តាប់ចម្លើយ សំ សិទ្ធី បញ្ជាក់ថា សាក្សីនេះ រួមជាមួយនឹងក្រុមគ្រួសាររបស់គាត់ ត្រូវបានជម្លៀសចេញពីលំនៅដ្ឋានរបស់គាត់នៅភូមិផ្អេរ ស្រុកកំពង់ឆ្នាំង នៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥[10]។ គ្រួសាររបស់គាត់បានធ្វើដំណើរដោយថ្មើរជើងអស់រយៈពេលជាងពីរសប្តាហ៍ រហូតពួកគាត់ទៅដល់វត្តច្រកស្តេច នៅក្នុងឃុំពាម ស្រុកសាមគ្គីមានជ័យ។ យោងតាមកំណត់ហេតុនៃការស្តាប់ចម្លើយនេះ នៅវត្តច្រកស្តេច កងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជា បានស្នើឲ្យអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរទាំងអស់ចុះឈ្មោះដើម្បីបើកអង្ករ។ គ្រួសាររបស់ សំ សិទ្ធី ត្រូវបានដាក់បញ្ចូលជាក្រុមជាមួយនឹង៦គ្រួសារផ្សេងទៀត ហើយក្រោយមកត្រូវបាននាំដើរកាន់ព្រៃ "ដែលមានខ្មែរក្រហមម្នាក់បង់កក្រមាជាអ្នកនាំផ្លូវ"។ នៅពេលទៅដល់អូរមួយនៅព្រៃរូងខ្លា បុរសៗពេញកម្លាំងនៅក្នុងក្រុមរបស់គាត់ដែលមានចំនួន១២នាក់ ត្រូវបានបញ្ជាឲ្យចូលទៅក្នុងព្រៃដើម្បីកាប់ឈើ។ សំ សិទ្ធី បានដើរតាមពួកនោះ រហូតដល់គាត់ "បានឃើញពួកខ្មែរក្រហម ៥-៦នាក់ ចេញពីក្នុងព្រៃមកភ្ជង់កាំភ្លើង" ហើយនាំបុរសៗទាំងនោះចូលទៅក្នុងព្រៃទៅ។ សំ សិទ្ធី បានរត់ត្រឡប់មករកម្តាយរបស់គាត់វិញនៅឯអូរ។ ប្រហែលជាជិតមួយម៉ោងក្រោយមក ខ្ញុំបានឮស្នូរកាំភ្លើងបាញ់នៅក្នុងព្រៃតាមទិសដែលគេបណ្តើរក្រុមបុរសៗទាំងនោះទៅ។ បន្ទាប់មក កម្មាភិបាលដែលនាំមនុស្សទាំង ៧ គ្រួសារនោះទៅកាន់ព្រៃរូងខ្លា បានត្រឡប់មកវិញ ហើយនាំស្ត្រី និងកុមារចូលទៅក្នុងព្រៃ ហើយពួកខ្មែរក្រហមក៏បានចេញមកភ្ជង់កាំភ្លើងទៀត

---

[10] ឯកសារ **E3/5201** "កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ សិទ្ធី" ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០៨ ("កំណត់ហេតុនៃការស្តាប់ចម្លើយ សំ សិទ្ធី") ERN 00275139-140។

បណ្ដើរក្រុមនោះទៅក្បែររណ្ដៅ បេ-៥២។ សមាជិកនៃក្រុមគ្រួសារទាំង៧គ្រួសារដែលនៅសេសសល់នេះ ត្រូវបានសម្លាប់ចោល លើកលែងតែ សំ សិទ្ធី ប្អូនស្រី១នាក់ និងប្អូនជីដូនមួយរបស់គាត់២នាក់ទៀត នៅរស់រានមានជីវិត ដោយសារតែ សំ សិទ្ធី ខ្លួនគាត់ធ្វើពុតជាស្លាប់។

5. ការរៀបរាប់នេះ តាមជាក់ស្ដែង គឺមិនទំនងទាល់តែសោះ ហើយផ្ទុយគ្នាទៅនឹងកំណត់ហេតុ។ សំ សិទ្ធី បានឆ្លើយផ្ទុយគ្នាជាច្រើនលើក ក្នុងអំឡុងពេលនៃការផ្ដល់សក្ខីកម្មរបស់គាត់នៅចំពោះមុខអង្គជំនុំជម្រះនេះ។

## ក. សំ សិទ្ធី មិនអាចបញ្ជាក់អំពីព័ត៌មានសំខាន់បំផុត ពាក់ព័ន្ធនឹងការស្ដាប់ចម្លើយរបស់គាត់ពីសំណាក់ ស.ច.ស

6. ទោះបីជាកំណត់ហេតុនៃការស្ដាប់ចម្លើយ ដែលមានឈ្មោះ សំ សិទ្ធី ចុះកាលបរិច្ឆេទថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០០៨ ក៏ដោយ ក៏ សំ សិទ្ធី បានផ្ដល់សក្ខីកម្មម្ដងហើយម្ដងទៀតថា គាត់ត្រូវបានសម្ភាសន៍កាលពីមួយឆ្នាំទៅពីរឆ្នាំមុន មុនពេលគាត់ចូលមកបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះ[11]។ ទោះបីជាក្រោយពីពិនិត្យមើលឡើងវិញលើកំណត់ហេតុនៃការស្ដាប់ចម្លើយរបស់គាត់ និងបន្ទាប់ពីមានការសួរសំណួរជាច្រើនពីអង្គជំនុំជម្រះ និងមេធាវីការពារក្ដីយ៉ាងណាក៏ដោយ ក៏គាត់បានបដិសេធថាមិនបានផ្ដល់ចម្លើយនៅក្នុងឆ្នាំ ២០០៨ ឡើយ[12]។ ទោះបីជា សំ សិទ្ធី អាចនៅចាំបានថា គាត់ត្រូវបាន "សម្ភាសន៍តែមួយដង"[13] ក៏ដោយ ក៏គាត់បានបញ្ជាក់ប្រាប់យ៉ាងជាក់លាក់ថា ការជួបសម្ភាសន៍នេះ បានកើតឡើងមិនលើសពីពីរឆ្នាំ មុនពេលគាត់ចូលមកបង្ហាញខ្លួនផ្ដល់សក្ខីកម្មនេះឡើយ ហើយគាត់ថែមទាំងបដិសេធដោយឆ្លើយផ្ទុយទៅនឹងការលើកឡើងដដែលៗរបស់មេធាវីការពារក្ដីទៀតផងថា៖ "ការជួបសម្ភាសន៍នោះ មិនមែន ៧ឆ្នាំ មុនទេ គឺ ២ឆ្នាំ មុននេះប៉ុណ្ណោះ។ តែបើនិយាយថា ៧ឆ្នាំ មុនហ្នឹង គឺខ្ញុំមិនឯកភាពទេ"[14]។

7. នៅពេលបន្តិចក្រោយមកទៀតនៅក្នុងថ្ងៃនោះ សំ សិទ្ធី ជាបណ្ដើរៗបានកែតម្រូវការចងចាំរបស់គាត់ ដើម្បីឲ្យត្រូវទៅនឹងអង្គហេតុដែលមេធាវីការពារក្ដីបានដាក់ទៅលើរូបគាត់ និងអង្គហេតុនៅ

---

[11] ឯកសារ **F1/2.1** "ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីបណ្ដឹងសាទុក្ខក្នុងសំណុំរឿង ០០២" (សំ សិទ្ធី) ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០១៥ (ប្រតិចារឹកនៃសក្ខីកម្មរបស់របស់ សំ សិទ្ធី") ទំព័រ ៦-៨។

[12] *ដូចយោងខាងលើ* ទំព័រ ៩។

[13] *ដូចយោងខាងលើ* ទំព័រ ៧។

[14] *ដូចយោងខាងលើ* ទំព័រ ៩។ សូមមើលផងដែរ ទំព័រ ១១។

ក្នុងឯកសារនៅចំពោះមុខគាត់។ ដំបូង គាត់បានកែប្រែសក្ខីកម្មរបស់គាត់ថា គាត់ត្រូវបានជួបសម្ភាសន៍តែមួយដងប៉ុណ្ណោះ ដោយអះអាងថា "មានពីរបីក្រុម"[15] ចុះទៅជួបសម្ភាសន៍គាត់ហ្នឹង។ ទោះបីជាគាត់ពីដំបូងមិនអាចចាំបានអំពីព័ត៌មានលម្អិតនៃក្រុមការងារណាមួយក្នុងចំណោម "ក្រុមការងារ" ទាំងនេះក៏ដោយ ក៏ក្រោយមកទៀតគាត់បានបញ្ជាក់ថា "ក្រុមខ្លះមកពីសារព័ត៌មាន ហើយក្រុមខ្លះទៀតមកពីអង្គការ"[16]។ ទោះបីយ៉ាងណាក៏ដោយ ពីដំបូងគាត់បានអះអាងថា ក្រុមការងារទាំងអស់នេះ បានដឹងអំពីរឿងរ៉ាវរបស់គាត់តាមរយៈអត្ថបទសារព័ត៌មាន ដែលចុះផ្សាយប្រហែលជាពីរឆ្នាំមុនការចូលមកបង្ហាញខ្លួនរបស់គាត់នៅចំពោះមុខអង្គជំនុំជម្រះនេះ[17]។ ប៉ុន្តែ នៅពេលចុងបញ្ចប់នៅថ្ងៃនោះ សំ សិទ្ធី បានកែប្រែចម្លើយវិញ៖ គាត់បានសន្និដ្ឋានថា តាមពិត គាត់ត្រូវបានគេ "ជួបសម្ភាសន៍៧ឆ្នាំមុនមួយដង ហើយ ២ ឆ្នាំមុនហ្នឹងមួយដង"[18]។

8. ភាពផ្ទុយគ្នាទាំងនេះចំពោះបញ្ហាដ៏សាមញ្ញមួយដូចជាកាលបរិច្ឆេទនៃការស្ដាប់ចម្លើយរបស់ សំ សិទ្ធី ពីសំណាក់ ស.ច.ស បានបង្ហាញឲ្យឃើញនូវលក្ខណៈមួយដែលគួរឲ្យព្រួយបារម្ភណ៍នៃព្រឹត្តិការណ៍នានាដែលកើតឡើងបន្តបន្ទាប់មកទៀត។ សំ សិទ្ធី មិនត្រឹមតែឆ្លើយផ្ទុយគ្នាទាំងនៅក្នុងកំណត់ហេតុនៃការស្ដាប់ចម្លើយនៅក្នុងសំណុំរឿង និងសក្ខីកម្មរបស់គាត់ផ្ទាល់នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលប៉ុណ្ណោះទេ តែថែមទាំងបានបង្ហាញឲ្យឃើញថា ខ្លួនគាត់ងាយទទួលយកនូវការលើកឡើង និងយល់ស្របតាមរាល់ការរៀបរាប់អំពីព្រឹត្តិការណ៍នានាដែលដាក់បង្ហាញដល់រូបគាត់នៅក្នុងតុលាការទៀតផង សូម្បីនៅពេលដែលវាមានលក្ខណៈផ្ទុយគ្នាទាំងស្រុងទៅនឹងចម្លើយពីមុនដែលបានផ្ដល់ជូនតែត្រឹមពីរបីនាទីមុននោះប៉ុណ្ណោះ។ នេះគឺជាការពិចារណាដ៏សំខាន់មួយ នៅក្នុងការវាយតម្លៃរបស់អង្គជំនុំជម្រះនេះ អំពីភាពគួរឲ្យជឿជាក់បានរបស់សាក្សីម្នាក់ដែលអះអាងថា ពិពណ៌នាអំពីព្រឹត្តិការណ៍នានាដែលត្រូវបានរាយការណ៍ថាបានកើតឡើងយ៉ាងទូលំទូលាយនោះ។

## ខ. សំ សិទ្ធី បានរៀបរាប់ផ្ទុយគ្នាទាំងស្រុងអំពីព្រឹត្តិការណ៍នានា បន្ទាប់ពីក្រុមគ្រួសាររបស់គាត់បាន

---

[15] *ដូចយោងខាងលើ* ទំព័រ ៥១។

[16] *ដូចយោងខាងលើ* ទំព័រ ៥៣។

[17] *ដូចយោងខាងលើ* ទំព័រ ៤៩-៥១ ("គេចុះមកជួបសម្ភាសន៍ខ្ញុំ ដោយសារមានការចុះផ្សាយក្នុងទំព័រកាសែត។ មានពីរបីក្រុមឯណោះចុះមកជួបសម្ភាសន៍ខ្ញុំ") ទំព័រ ៥៣ ("ហើយអ្នកដែលទៅជួបសម្ភាសន៍ខ្ញុំហ្នឹង គឺទៅសម្ភាសន៍ខ្ញុំក្នុងអំឡុង ២ឆ្នាំមុន។ មានពីរបីក្រុមឯណោះទៅជួបសម្ភាសន៍ខ្ញុំហ្នឹង គឺមានទាំងក្រុមអ្នកសារព័ត៌មាន និងក្រុមខាងអង្គការ")។

[18] *ដូចយោងខាងលើ* ទំព័រ ១១០។

**មកដល់ព្រៃរូងខ្លា**

9. ទោះបីជាមេធាវីការពារក្តីបានសួរសំណួរបើកជាច្រើន ពាក់ព័ន្ធនឹងលំដាប់លំដោយនៃព្រឹត្តិការណ៍នានាដែលបានកើតឡើង ចាប់ពីពេលដែល សំ សិទ្ធី ចាកចេញពីវត្តច្រកស្តេច រហូតដល់គាត់រត់គេចខ្លួនពីព្រៃរូងខ្លាយ៉ាងណាក៏ដោយ ក៏សាក្សីរូបនេះបានបដិសេធជាច្រើនលើកមិនផ្តល់នូវព័ត៌មានលម្អិតដែលស៊ីសង្វាក់គ្នាសូម្បីតែបន្តិចឡើយ។ គាត់ពុំបានបញ្ជាក់អំពីការបែកចេញពីឪពុករបស់គាត់ ការដើរឆ្លងកាត់ទន្លេ ការដើរតាមបុរសៗពេញកម្លាំងទាំងនោះ ការឃើញមនុស្សប្រដាប់ដោយកាំភ្លើងចេញពីក្នុងព្រៃ និងការរត់ទៅពន្យល់ប្រាប់ម្តាយរបស់គាត់ដោយឥតប្រយោជន៍អំពីគ្រោះថ្នាក់ដែលនឹងកើតឡើងក្នុងពេលឆាប់ៗខាងមុខ។ ផ្ទុយទៅវិញ គាត់បាន រៀបរាប់អំពីលំដាប់លំដោយនៃព្រឹត្តិការណ៍ជាហូរហែដែលមានលក្ខណៈមិនច្បាស់លាស់ទាល់តែសោះ ដោយចាប់ផ្តើមពីការចេញដំណើររបស់គាត់ពីវត្តច្រកស្តេច រហូតទៅដល់ការសម្លាប់ក្រុមគ្រួសារទាំង៧គ្រួសារនោះនៅទីកន្លែងមួយនៅព្រៃរូងខ្លា។ ការសន្ទនាគ្នាខាងក្រោមនេះ អំពីការធ្វើដំណើរដោយថ្មើរជើងប្រហែលជាមួយម៉ោងចេញពីវត្តច្រកស្តេចឆ្ពោះទៅព្រៃរូងខ្លា គឺជាឧទាហរណ៍បញ្ជាក់៖

ស. ដូច្នេះលោក និងក្រុមគ្រួសាររបស់លោកចាកចេញពីវត្តច្រកស្តេច។ សូមប្រាប់តុលាការមកថាមានអ្វីកើតឡើង?

ឆ. បាទ នៅពេលដែលចេញផុតពីវត្តច្រកស្តេចទៅ គឺគេយកឆ្លងអូរមួយ ហើយគេឲ្យយើងដាក់សម្ពាយសម្ភារៈហ្នឹងនៅខាងត្បូងអូរ ហើយគេឲ្យយើងដើរទៅ--ខាងជើងអូរហើយគេនាំតែមនុស្សដែលគ្មានកាន់បង្វេចអីទៅជាមួយទេ ឆ្លងអូរទៅខាងត្បូង។ ឆ្លងអូរទៅខាងត្បូង នៅពេលដែលឆ្លងមាត់អូរហ្នឹងទៅ គឺកងកម្លាំងយោធាគេដែលប្រើប្រាស់ដោយអាវុធនោះ គេមកឆ្លុកយកតែម្តង យកទៅសម្លាប់តែម្តង។

[...]

ស. មិនអីទេលោកសាក្សី ខ្ញុំបន្តទៅមុខទៀត។ លោកដើរជាមួយគ្រួសារចំនួនប្រាំពីរគ្រួសារ។ ដូច្នេះខ្ញុំចង់ដឹងថា តើមានអ្វីកើតឡើងបន្តទៀត?

ឆ. <u>អត់មានអីកើតឡើងតទៅទៀតទេ</u> ពីព្រោះគេសម្លាប់ចោលអស់ហើយ។ ហើយខ្ញុំហ្នឹងរួចពីស្លាប់។ សល់ពីស្លាប់ហ្នឹងបួននាក់ ប្អូនស្រីពីរ ជីដូនមួយពីរនាក់ និងបងប្អូនបង្កើតខ្ញុំពីរនាក់ប្រុសមួយស្រីមួយ។

ស. លោកសាក្សី លោកជាអធិការប៉ូលីស លោកដឹងទេថាខ្ញុំកំពុងសួរលោកលម្អិត ដូច្នេះសូម

លោកជម្រាបឲ្យបានលម្អិតបន្តិចថាមានអ្វីកើតឡើង។ លោកនិយាយថា លោកដើរទៅជាមួយក្រុមគ្រួសារចំនួនប្រាំពីរគ្រួសារ ដូច្នេះតើលោកអាចប្រាប់លម្អិតបានទេថាបន្ទាប់មកតើមានអ្វីកើតឡើង? តើលោកឃើញអ្វី? តើលោកឮអ្វី?

ឆ. ខ្ញុំបានឃើញថា នៅពេលដែលធ្វើដំណើរទៅ គឺមានកងទ័ពប្រដាប់អាវុធ ពេលឆ្លងអូរមួយហ្នឹងទៅ គឺមានកងទ័ពប្រដាប់អាវុធមកភ្ជង់យកទៅចូលក្នុងរូងព្រៃខ្លាហ្នឹងឯង ហើយធ្វើការកាប់សម្លាប់ បាញ់សម្លាប់។

ស. មានម្តងនោះលោកនិយាយថា លោកឃើញទាហានប្រដាប់អាវុធ។ តើពួកគេធ្វើអ្វី? ពួកគេនិយាយអ្វី? សូមលោកជម្រាបដល់តុលាការឲ្យបានច្បាស់ នៅពេលដែលក្រុមប្រជាជនហ្នឹងឃើញទាហានទាំងអស់ហ្នឹង តើមានអ្វីកើតឡើង?

ឆ. បាទ នៅពេលដែលគេបណ្តើរទៅ គឺគេភ្ជង់កាំភ្លើងយើងទៅ ហើយគេប្រាប់ថាឲ្យដើរទៅមុខត្រង់ កុំរត់ បើរត់បាញ់ចោល។ នៅពេលដែលគេបណ្តើរយើងទៅដល់ គេឲ្យយើងអង្គុយម៉ុំទាំងប្រាំពីរគ្រួសារហ្នឹងគឺអង្គុយម៉ុំ[19]។

10. សំខាន់ជាងនេះទៀត សំ សិទ្ធី បានប្រកាន់ខ្ជាប់ទៅនឹងការរៀបរាប់អំពីព្រឹត្តិការណ៍នេះ សូម្បីតែបន្ទាប់ពីគាត់ត្រូវបានចោទសួរនូវសំណួរយ៉ាងជាក់លាក់អំពីប្រតិកម្មរបស់ឪពុករបស់គាត់ ដែលត្រូវបានសន្និដ្ឋានថាបានស្លាប់បាត់ទៅហើយ ជាមួយនឹងទាហាននៃកងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជា ដែលបានបណ្តើរគាត់យកចេញទៅពីអូរនៅព្រៃរូងខ្លានោះ៖

ស. តើប្រជាជននៅក្នុងក្រុមហ្នឹងមានប្រតិកម្មអ្វីដែរ? តើមានការពិភាក្សាគ្នារវាងឪពុកលោកនិងទាហានទាំងអស់នោះដែរឬទេ? តើមានអ្វីកើតឡើង?

ឆ. អត់បានពិភាក្សាគ្នាអីទេ ព្រោះយើងអត់មានអាវុធអីជាប់ខ្លួន សូម្បីតែកាំបិត ពូថៅហ្នឹងក៏អត់មានផង គឺគេឲ្យដាក់សម្ភារៈហ្នឹងម៉ុំ ហើយខាងជើងអូរ ហើយគេនាំមនុស្សហ្នឹងដើរទៅខាងត្បូងអូរ។ ក្រោយពេលដើរទៅខាងត្បូងអូរហើយ មានកម្លាំងប្រដាប់អាវុធនោះ មក

---

[19] *ដូចយោងខាងលើ* ទំព័រ ២២-២៤។ ការរៀបរាប់មិនច្បាស់លាស់ស្រដៀងគ្នានេះដែរ មានពាសពេញនៅក្នុងសក្ខីកម្មរបស់ សំ សិទ្ធី។ សូមមើល ឧទាហរណ៍ ដូចយោងខាងលើ ទំព័រ ១៥-១៦ ("ដល់តែពេលដើរទៅដល់ព្រៃរូងខ្លា យើងធ្វើដំណើរតាំងពីម៉ោងមួយ រហូតទៅដល់ព្រៃរូងខ្លានេះ គឺគេឲ្យយើងដាក់សំពាយ បង្វេចនៅម្ខាងអូរខាងនេះ ខាងជើង ហើយគេឲ្យដើរតែខ្លួនចេញទៅខាងត្បូងអូរ។ នៅពេលដើរទៅដល់ខាងត្បូងអូរនោះ គឺមានកងទ័ពប្រដាប់អាវុធ មកភ្ជង់ ហើយឲ្យអង្គុយម៉ុំ ហើយគេបាញ់ផ្ទុចសម្លាប់ទាំងអស់")។

ភ្លង់យកទៅសម្លាប់តែម្តង[20]។

11. បន្ទាប់ពីមេធាវីការពារក្តីរម្លឹកគាត់ពីខ្លឹមសារនៃកំណត់ហេតុស្តាប់ចម្លើយរបស់គាត់ ទើប សំ សិទ្ធី នឹកឃើញភ្លាមថាបានពន្យល់ថា ដំបូងគេបំបែកឪពុកគាត់ចេញពីអ្នកផ្សេងទៀតនៅក្នុងក្រុម រួមជាមួយមនុស្សប្រុសពេញវ័យផ្សេងទៀត[21]។ មិនមែនជាប្រការគួរឲ្យភ្ញាក់ផ្អើលទេ សក្ខីកម្មរបស់ សំ សិទ្ធី ចំពោះផ្នែកនេះនៃសាច់រឿងរបស់ខ្លួនមានការប្រែប្រួលជាបន្តបន្ទាប់ ក្នុងអំឡុងពេលនៃការផ្តល់សក្ខីកម្មរបស់គាត់ និងនៅក្នុងចំណុចសំខាន់ៗ គាត់បានឆ្លើយងាកចេញពីកំណត់ហេតុស្តាប់ចម្លើយរបស់គាត់។ កំណត់ហេតុស្តាប់ចម្លើយបានបង្ហាញថា នៅពេលគាត់ទៅតាមឪពុកគាត់ សាក្សី "បានឃើញពួកខ្មែរក្រហម ៥-៦ នាក់ ចេញពីក្នុងព្រៃមកភ្លង់កាំភ្លើង" បណ្តាលឲ្យគាត់រត់ទៅម្តាយគាត់វិញ។ ប្រហែលជិតមួយម៉ោងក្រោយមក គាត់បានឮស្នូរកាំភ្លើង ដែលធ្វើឲ្យគាត់សន្និដ្ឋានថា ឪពុកគាត់បានស្លាប់ហើយ[22]។ សក្ខីកម្មរបស់គាត់នៅចំពោះមុខអង្គជំនុំជម្រះនេះខុសគ្នាទាំងស្រុង៖

> នៅពេលដែលខ្ញុំរត់តាមឪពុកខ្ញុំទៅហ្នឹង គឺគេដេញឲ្យមកក្រោយវិញ ដោយសារយើងនៅតូច។ គេយកតែមនុស្សដែលពេញកម្លាំងទៅកាប់ឈើ ធ្វើជម្រកនៅ។ ហើយដល់ពេលខ្ញុំឈរមើលគេ ខ្ញុំលបឈរមើលគេ ក្រោយពេលគេយកឪពុកខ្ញុំចូលដល់ព្រៃខ្លាហ្នឹងហើយ គេបាញ់សម្លាប់ហើយ ខ្ញុំរត់មកក្រោយវិញ។ ដល់ខ្ញុំរត់មកក្រោយវិញ ខ្ញុំមកប្រាប់មីងមា ម៉ែម្តាយនៅខាងក្រោយឲ្យនាំគ្នារត់ គាត់មិនរត់។ ហើយគេសម្លាប់ឪពុកខ្ញុំអស់ហើយ[23]។

មួយម៉ោងក្រោយមក សាក្សីបានផ្តល់សក្ខីកម្មទីបីថា៖

> គេយកតែមនុស្សពេញកម្លាំងយកទៅមុន ជាប្រុស យកទៅមុន។ ហើយខ្ញុំហ្នឹងតូចជាងគេរត់តាមឪពុកទៅ ហើយគេដេញមកក្រោយវិញ ដេញឲ្យមកនៅជាមួយម្តាយវិញ អត់ឲ្យទៅជាមួយឪពុកទេ។ តែខ្ញុំមិនមក ខ្ញុំនៅលួចមើលសកម្មភាពហ្នឹងបណ្តើរចូលផុតព្រៃផុតអូរហ្នឹងទៅ គឺប្រាំមួយនាក់ហ្នឹងចេញមកភ្លង់យកទៅតែម្តង។ ហើយមួយស្របក់ក្រោយមក ឮស្នូរផ្ទុះអាវុធ ខ្ញុំរត់មកប្រាប់ម្តាយ មីងមាខាងក្រោយនេះ ថាឲ្យនាំគ្នារត់ទៅ គេយកប៉ាទៅបាញ់ចោលអស់ហើយ។ គាត់អត់ជឿ [...]។ គ្រាន់តែពេលដែលបាញ់ប្រាវ

[20] *ដូចយោងខាងលើ* ទំព័រ ២៤។

[21] *ដូចយោងខាងលើ* ទំព័រ ២៥។

[22] កំណត់ហេតុស្តាប់ចម្លើយរបស់ សំ សិទ្ធី លេខ ERN 00275139។

[23] ប្រតិចារឹកសក្ខីកម្មរបស់ សំ សិទ្ធី ទំព័រ ៣៥ (គូសបញ្ជាក់បន្ថែម)។

ហើយ ខ្ញុំរត់មកក្រោយវិញ ខ្ញុំមកប្រាប់គាត់ឲ្យនាំគ្នារត់ ហើយគាត់មិនជឿខ្ញុំ[24]។

សំ សិទ្ធី មិនអាចចងចាំថាតើគាត់ភ័យខ្លាចដោយបានឃើញកម្មាភិបាលមានកាំភ្លើង ឬដោយសារឪពុកគាត់ត្រូវបានសម្លាប់យ៉ាងព្រៃផ្សៃនោះទេ។ គាត់មិនអាចចងចាំថាតើគាត់រត់ដោយសារការតាំងចិត្តរបស់ខ្លួន ឬដោយសារមានគេដេញគាត់ទេ។ គាត់មិនអាចចងចាំថាតើគាត់បាននៅរង់ចាំយ៉ាងអំណត់ជាមួយម្ដាយ និងមីងគាត់រយៈពេលមួយម៉ោងពេញ រហូតដល់ពេលគាត់ឮស្នូរកាំភ្លើងពីចម្ងាយ ឬយ៉ាងណា តើគាត់បានលាក់ខ្លួននៅក្នុងព្រៃ និងត្រឡប់ទៅជួបម្ដាយគាត់វិញក្រោយពេលឮស្នូរកាំភ្លើងទាំងនោះ ឬយ៉ាងណា ឬតើគាត់បានឃើញការសម្លាប់បង្ហូរឈាមឪពុកគាត់មុនពេលគាត់ត្រឡប់ទៅជួបម្ដាយគាត់វិញ ដែលគេសន្មតថា ប្រកបដោយការភ័យស្លន់ស្លោអារម្មណ៍ក្ដុកក្ដួល ឬយ៉ាងណាទេ។

12. នៅពេលប្រឈមមុខនឹងចម្លើយផ្ទុយគ្នាទាំងនេះ សំ សិទ្ធី មិនអាចធ្វើឲ្យចម្លើយទាំងនេះស្របគ្នាបានទេ។ ផ្ទុយទៅវិញ គាត់បានប្ដូរចម្លើយរបស់ខ្លួនទៅតាមសក្ខីកម្មដែលគាត់បានផ្ដល់នៅក្នុងកំណត់ហេតុស្ដាប់ចម្លើយ បន្ទាប់ពីមេធាវីការពារក្ដីបានអានផ្នែកដែលពាក់ព័ន្ធឲ្យគាត់ស្ដាប់ភ្លាម។ យុទ្ធវិធីនេះដូចបេះបិទទៅនឹងយុទ្ធវិធីដែលគាត់បានប្រើ ក្នុងការឆ្លើយតបទៅនឹងការរម្លឹកពីមុនរបស់មេធាវីដែលថា ប្រុសៗត្រូវបានបំបែកពីស្ត្រីមុនពេលយកទៅសម្លាប់[25]។ ហេតុនេះ សំ សិទ្ធី បានផ្ដល់សក្ខីកម្មថា គាត់បានទៅតាមឪពុកគាត់ រហូតគាត់បានឃើញកងកម្លាំងប្រដាប់អាវុធចេញពីក្នុងព្រៃ និងដកអាវុធចេញមក (មិនមែនពេលគាត់ឮស្នូរកាំភ្លើង ឬនៅពេលគាត់ឃើញកាំភ្លើងបានបាញ់ចេញទេ) ទើបគាត់រត់ត្រឡប់ទៅជួបម្ដាយគាត់វិញ (ជំនួសឲ្យការដេញទៅវិញ) ហើយថា គាត់បានឮស្នូរកាំភ្លើងប្រហែលមួយម៉ោងក្រោយពេលគាត់បានទៅជួបម្ដាយវិញហើយ (មិនមែនថា គាត់បានរត់ត្រឡប់ទៅជួបម្ដាយវិញភ្លាម ក្រោយពេលគាត់បានឮស្នូរកាំភ្លើងទេ)។ សាក្សីណាដែលនិយាយសម្របសាច់រឿងរបស់ខ្លួន ទៅតាមអ្វីដែលគេបង្ហាញឲ្យគាត់ឃើញ សាក្សីនោះមិនគួរឲ្យជឿជាក់បានទេ។

13. សំ សិទ្ធី បានឆ្លើយផ្ទុយបន្ថែមទៅទៀតទៅនឹងសក្ខីកម្មរបស់គាត់ពីពេលដែលសមាជិកគ្រួសារគាត់ត្រូវបានបំបែកនៅអូរក្នុងព្រៃរូងខ្លា ជាមួយមនុស្សប្រុសពេញវ័យផ្សេងទៀត។ នៅក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់គាត់ សំ សិទ្ធី អះអាងថា ក្រោយពេលប្រុសៗត្រូវបាននាំទៅព្រៃរូងខ្លា នៅសល់

---

[24] *ដូចយោងខាងលើ* ទំព័រ ៦១។

[25] *ដូចយោងខាងលើ* ទំព័រ ៦២ ដល់ ៦៥។

តែ "នារីៗ និងកុមារ" ទេ[26]។ គាត់ពិពណ៌នាស្រដៀងគ្នាពីពេលវិលត្រឡប់ទៅ "ក្រុមនារីៗ រួមទាំងម្តាយ និងប្អូនៗខ្ញុំផង ដែលមានមនុស្សប្រហែល ៣០ នាក់" ក្រោយពេលតាមប្រុសៗទៅក្នុងព្រៃ[27]។ ប៉ុន្តែ ក្នុងអំឡុងពេលគាត់មានវត្តមាននៅចំពោះមុខអង្គជំនុំជម្រះនេះ សំ សិទ្ធី បានផ្តល់សក្ខីកម្មជាច្រើនដងថា "មា" នៅជាមួយម្តាយ និងមីងគាត់ ក្រោយពេលឪពុកគាត់ត្រូវបានសន្មតថា ត្រូវបានយកទៅសម្លាប់[28]។ គាត់អះអាងថា គាត់នៅចាំបានយ៉ាងជាក់លាក់ថា គាត់មានវត្តមាននៅ "កន្លែងសម្លាប់មនុស្ស" ដែល "ម្តាយ មីងមា" របស់គាត់គឺ "ត្រូវគ្រាប់កាំភ្លើង"[29]។ ត្រឹមតែជាងបីម៉ោងក្រោយមក សំ សិទ្ធី បានឆ្លើយផ្ទុយម្តងទៀតទៅនឹងចម្លើយពីមុនរបស់ខ្លួន ដោយឆ្លើយត្រឡប់ទៅរកកំណត់ហេតុស្តាប់ចម្លើយរបស់គាត់ ដោយអះអាងថា មាគាត់ និងកូនៗរបស់ពួកគេដែលធំដឹងក្តី ត្រូវបាននាំយកទៅជាមួយប្រុសៗ[30]។ បន្ទាប់មក គាត់ "បានរត់មកក្រោយវិញ មកប្រាប់ម្តាយ និងមីងខ្ញុំ" មាគាត់លែងមានវត្តមានហើយ "ថាគេយកប៉ាទៅសម្លាប់ហើយ"[31]។

## គ. សំ សិទ្ធី បានផ្តល់សក្ខីកម្មមិនស្របគ្នាសោះទាក់ទិននឹងសមាជិកគ្រួសារគាត់ដែលបានរស់រានមានជីវិត

14. សំ សិទ្ធី ក៏បានផ្តល់សក្ខីកម្មផ្ទុយគ្នាដែលទាក់ទិននឹងចំនួន និងអត្តសញ្ញាណសមាជិកគ្រួសារគាត់ដែលនៅរស់រានមានជីវិតពីឧបទ្ទវហេតុដែលបានចោទប្រកាន់នោះ។ សំ សិទ្ធី បានផ្តល់សក្ខីកម្មថា គាត់ជាកូនច្បងក្នុងចំណោមកូនប្រាំនាក់ ដែលមានប្អូនស្រីពីរនាក់ និងប្អូនប្រុសពីរនាក់[32]។ គាត់បានផ្តល់សក្ខីកម្មថា នៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ គាត់រស់នៅជាមួយប្អូនបួននាក់ និងឪពុកម្តាយគាត់ក្នុងផ្ទះតែមួយ[33]។ សំ សិទ្ធី អះអាងថា ក្នុងអំឡុងពេលមានឧបទ្ទវហេតុនៅព្រៃវែងខ្លា

---

[26] កំណត់ហេតុស្តាប់ចម្លើយរបស់ សំ សិទ្ធី លេខ ERN 00275139។

[27] *ដូចយោងខាងលើ* លេខ ERN 00275139។

[28] ប្រតិចារឹកសក្ខីកម្មរបស់ សំ សិទ្ធី ទំព័រ ៣៥។ ទោះបី មិនច្បាស់ទាំងស្រុងក្នុងអំឡុងពេល សំ សិទ្ធី ផ្តល់សក្ខីកម្មថាតើ "មា" ដែលគាត់ពិពណ៌នានោះ ជាបងប្អូនប្រុសរបស់ឪពុកម្តាយគាត់ ឬសាច់ញាតិប្រុសៗផ្សេងទៀតរបស់គាត់ ឬយ៉ាងណាក៏ដោយ តែច្បាស់ថា អ្នកទាំងនោះជាមនុស្សប្រុស។

[29] *ដូចយោងខាងលើ* ទំព័រ ៣៨។

[30] *ដូចយោងខាងលើ* ទំព័រ ៩៦, ១១៧។

[31] *ដូចយោងខាងលើ* ទំព័រ ២៦ (គូសបញ្ជាក់បន្ថែម)។

[32] *ដូចយោងខាងលើ* ទំព័រ ១២, ៨៩។

[33] *ដូចយោងខាងលើ* ទំព័រ ៨៩។

"ប្អូនពីរនាក់ត្រូវសម្លាប់"[34]។ ប៉ុន្តែ សំ សិទ្ធី ក៏បានផ្តល់សក្ខីកម្មថា ក្នុងចំណោមប្អូនគាត់បួននាក់ នៅរស់តែម្នាក់ទេ[35]។ ហេតុនេះ សំ សិទ្ធី មិនបានផ្តល់សក្ខីកម្មស៊ីសង្វាក់គ្នាទេ សូម្បីតែចំនួនប្អូនគាត់ត្រូវបានសម្លាប់ប៉ុន្មាននាក់នោះ។

## ឃ. សំ សិទ្ធី ផ្តល់សក្ខីកម្មផ្ទុយគ្នាពីការដែលគាត់វិលត្រឡប់ទៅវត្តច្រកស្តេច

15. សំ សិទ្ធី បានផ្តល់សក្ខីកម្មថា នៅពេលគាត់គេចផុតពីរណ្តៅគ្រាប់ បេ-៥២ គាត់បានវិលត្រឡប់ទៅវត្តច្រកស្តេច ជាកន្លែងតែមួយដែលគាត់ និងគ្រួសារគាត់បានបែកគ្នាឆ្ពោះទៅព្រៃរូងខ្លា។ សំ សិទ្ធី បានផ្តល់សក្ខីកម្មថា ការធ្វើដំណើរពីវត្តច្រកស្តេចទៅព្រៃរូងខ្លាចំណាយពេលពីមួយទៅពីរម៉ោង[36]។ ប៉ុន្តែ សំ សិទ្ធី ក៏បានប្រាប់ ស.ច.ស ថា ដើម្បីធ្វើដំណើរតាមផ្លូវដដែលនេះត្រូវមកវិញ ពីព្រៃរូងខ្លាទៅវត្តច្រកស្តេច "ពួកខ្ញុំទាំងបួននាក់បងប្អូនបានរត់អស់រយៈពេល<u>មួយយប់</u>ទើបទៅដល់វត្តច្រកស្តេចវិញ"[37]។

16. បន្ទាប់មក សំ សិទ្ធី បានផ្តល់សក្ខីកម្មផ្ទុយគ្នាយ៉ាងច្បាស់ពីរបៀបដែលគេផ្តល់ព័ត៌មានពីការសម្លាប់មនុស្សនៅព្រៃរូងខ្លា ដល់មនុស្ស "រាប់ពាន់" នាក់ដែលបានប្រមូលផ្តុំគ្នានៅវត្តច្រកស្តេច។ ដំបូង សំ សិទ្ធី ផ្តល់សក្ខីកម្មជាច្រើនដងថា នៅពេលគាត់វិលត្រឡប់ទៅវត្តច្រកស្តេចវិញ ប្រជាជនដែលនៅប្រមូលផ្តុំគ្នានៅទីនោះបានដឹងរួចហើយថា ឪពុកម្តាយគាត់បានស្លាប់ទៅហើយ។ គាត់បានពន្យល់ថា៖

> ខ្ញុំដឹកនាំចូលទៅកាន់វត្តច្រកស្តេចនោះវិញ។ ទៅដល់វត្តច្រកស្តេចនោះហើយ <u>មានអ្នកស្គាល់ដែលជាៗបងប្អូនសាច់ញាតិ។ មានអ្នកស្គាល់គេឃើញខ្ញុំត្រូវគេបណ្តើរទៅចែក</u>អង្ករហើយ ជម្លៀសចេញទៅហើយ គេសួរៗរកឪពុកម្តាយ។ គេសួររកឪពុកម្តាយ ខ្ញុំសល់បងប្អូនបួននាក់ហ្នឹង ក៏សុំបាយគេហូបអីហើយ ខ្ញុំឡើបប្រាប់គេថា <u>ឪពុកម្តាយខ្ញុំត្រូវគេយកទៅបាញ់ចោលអស់ហើយ</u>។ ហើយនៅពេលនោះ កម្លាំងសន្តិសុខរបស់គាត់ គឺតាមស្រាវជ្រាវៗរកក្មេងប្អូននាក់ហ្នឹង[38]។

គាត់បានពន្យល់ម្តងទៀតថា៖

---

[34] *ដូចយោងខាងលើ* ទំព័រ ១២។

[35] *ដូចយោងខាងលើ* ទំព័រ ៤០, ៤៣ ដល់ ៤៤។

[36] *ដូចយោងខាងលើ* ទំព័រ ៥៨ ដល់ ៥៩។

[37] កំណត់ហេតុស្តាប់ចម្លើយរបស់ សំ សិទ្ធី លេខ ERN 00275140។

[38] ប្រតិចារឹកសក្ខីកម្មរបស់ សំ សិទ្ធី ទំព័រ ១៦។

ចេញពីរណ្ដៅសាកសពហ្នឹងមក គឺនាំគ្នាដឹកដៃប្អូនរត់ចូលទៅក្នុងវត្តហ្នឹង វត្តច្រកស្ដេចហ្នឹងវិញ ព្រោះវាដល់ម៉ោងឃ្លានហើយ។ ដល់តែចូលក្នុងហ្នឹងវិញ មានអ្នកស្គាល់ហ្នឹងគេឱ្យបាយ ឱ្យទឹក។ ហើយអ៊ីចឹងហើយ ខ្ញុំគ្រាន់តែបានតែខ្សឹបប្រាប់គេ ហើយដឹកនាំប្អូនរត់ជុំវិញហ្នឹងទាំងអស់ ដើរពីកន្លែងចល័តពីកន្លែងមួយទៅកន្លែងមួយ[39]។

17. ប៉ុន្តែ ក្រោយមក សំ សិទ្ធី បាននិយាយផ្ទុយពីនោះវិញថា៖

គេមិនសួរថា ប៉ាម៉ាក់អ្អែងទៅណា? ហើយខ្ញុំមិនលបខ្សឹបប្រាប់គេថា ប៉ាម៉ាក់ខ្ញុំគេយកទៅសម្លាប់ចោលអស់ហើយ។ ហើយនៅពេលនោះ វាឮពីក្អែកមួយក្អែកដប់ហើយហ្នឹង។ ឮពីម្នាក់ឆ្លើយទៅម្នាក់ ម្នាក់សួរម្នាក់ វាឆ្អើលពេញវត្តហ្នឹងទៅ ហើយខ្ញុំក៏ដឹកដៃប្អូនហ្នឹងរត់ ដើរក្រឡឹងជុំវិញវត្តហ្នឹង គេចខ្លួន[40]។

18. សំខាន់ជាងនេះគឺថា ភាពចាំបាច់នៃការឆ្លើយផ្ទុយគ្នានេះលើសពីសំណួរធម្មតាដែលថា តើប្រជាជនដែលប្រមូលផ្តុំគ្នានៅវត្តនោះបានដឹងពីព្រឹត្តិការណ៍នៅព្រៃរូងខ្លា មុនពេល សំ សិទ្ធី ទៅដល់ ឬយ៉ាងណា។ សំ សិទ្ធី បានផ្តល់សក្ខីកម្មទាំងនោះនៅចំពោះមុខ ស.ច.ស និងអង្គជំនុំជម្រះតុលាការកំពូលថា ពេលគាត់ត្រឡប់ទៅដល់វត្ត "ព័ត៌មានអំពីការសម្លាប់ឪពុកម្តាយខ្ញុំ និងមនុស្សផ្សេងទៀត បានលេចឮពេញវត្ត បណ្តាលឱ្យមានការជ្រួលច្របល់"[41]។ ការជ្រួលច្របល់នេះនាំឱ្យកងទ័ពជាតិរំដោះប្រជាជនកម្ពុជា ប្រកាសដាក់មេក្រូ ដោយព្រមានប្រាប់អ្នកជុំគ្នាកុំឱ្យជឿការឃោសនានេះ ហើយចុងក្រោយ ប្រជាជនរាប់ពាន់នាក់ចេញទៅរកភូមិកំណើតរបស់ខ្លួនវិញ។ ការកំណត់ពេលវេលានៃលំដាប់លំដោយទាំងមូលនេះអាស្រ័យលើការអះអាងរបស់ សំ សិទ្ធី ដែលថា គាត់បានពិពណ៌នាពីការសម្លាប់សាច់ញាតិដែលមិនបានដឹងព័ត៌មាននៅវត្តច្រកស្តេច ក្រោយពេលគាត់បានទៅដល់ ដោយបណ្តាលឱ្យសាច់រឿងនេះ "ឮពីម្នាក់ទៅម្នាក់" និងផ្អើលនាំគ្នាចេញពីវត្ត។ ប៉ុន្តែ សក្ខីកម្មភាគច្រើនរបស់ សំ សិទ្ធី នៅចំពោះមុខអង្គជំនុំជម្រះនេះគឺព័ត៌មានដែលបណ្តាលឱ្យមានការភ័យស្លន់ស្លោត្រូវបានដឹងរួចជាស្រេចទៅហើយ នៅពេលគាត់ទៅដល់វត្តនោះវិញ។ ចំណុចនេះផ្ទុយពីសុភវិនិច្ឆ័យដែលជឿថា សំ សិទ្ធី គ្រាន់តែច្រឡំអំពីព័ត៌មានលម្អិតសំខាន់នេះ ដែលបានសន្មតថាមានផលវិបាកសំខាន់ទាំងនេះ និងការរៀបចំឈុតឆាកសម្រាប់ដំណាក់កាលបន្ទាប់នៃដំណើររបស់គាត់។

---

[39] *ដូចយោងខាងលើ* ទំព័រ ៤០។

[40] *ដូចយោងខាងលើ* ទំព័រ ១១៨។

[41] កំណត់ហេតុស្តាប់ចម្លើយរបស់ សំ សិទ្ធី លេខ ERN 00275140។

## ង. ពុំមានភ័ស្តុតាងបញ្ជាក់

19. រួមជាជាមួយភាពចន្លោះប្រហោង និងមិនស៊ីសង្វាក់យ៉ាងខ្លាំងទាំងនេះ គឺពុំមានភ័ស្តុតាងណាបញ្ជាក់ទាល់តែសោះ។ ពុំមានសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះ ឬអ្នកសិក្សាស្រាវជ្រាវណានិយាយថាមានការប្រមូលផ្តុំ "វាប់ពាន់" គ្រួសារនៅវត្តច្រកស្តេច ហើយក៏ពុំមានការសម្លាប់នៅក្នុងបរិវេណវត្តនោះដែរ។ ពុំមានរកឃើញថាមានរណ្តៅសាកសពរួម ហើយការពិតមិនទាំងមានសាកសពមួយផងទេ។ ពុំមានការលើកឡើងពីវត្តច្រកស្តេចនៅក្នុងសំណុំរឿង សម្រាប់គោលបំណងណាមួយទេ។ មានការលើកឡើងតែមួយគត់អំពីច្រកស្តេចដែលគួរឲ្យចាប់អារម្មណ៍ពីជនភៀសខ្លួនម្នាក់ដែលត្រូវបានសម្ភាសដោយ Heder និង Matsushita ដែលបានផ្លាស់ទៅនៅក្នុងភូមិនោះនៅខែ ធ្នូ ឆ្នាំ ១៩៧៣ និង "មិនដែលឮថាមានចាប់ភ្នាក់ងារខ្មាំង ឬទាហាន លន់ នល់ អ្វីទេ"[42]។

20. ភ័ស្តុតាងតែមួយគត់ដែលមានផ្ទុយពីសក្ខីកម្មរបស់ សំ សិទ្ធី ដោយត្រង់ៗតែម្តង។ បើតាមគម្រោងគូសផែនទីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam) មានកន្លែងសម្លាប់មនុស្សមួយនៅកំពង់ឆ្នាំងដែលមានឈ្មោះថាព្រៃរូងខ្លា តែកន្លែងនោះមានចម្ងាយដល់ទៅ ៧០ គីឡូម៉ែត្រពីវត្តច្រកស្តេចនៅស្រុកបរិបូរ[43] ជាចម្ងាយផ្លូវដែល សំ សិទ្ធី អះអាងថា បានធ្វើដំណើរត្រឡប់ទៅវិញប្រហែលមួយម៉ោង។ ការពិត ព្រៃរូងខ្លា មិននៅជិតគន្លងផ្លូវនៃការធ្វើដំណើររបស់ សំ សិទ្ធី នៅខែ មេសា ឆ្នាំ ១៩៧៥ ទេ។ សំ សិទ្ធី បានពិពណ៌នាថា បានធ្វើដំណើរទៅទិសនិរតីពីភូមិផ្អេរ (ជិតក្រុងកំពង់ឆ្នាំង) ឆ្ពោះទៅ ខ្លុងពពក និងភ្នំជម្រាយ មុនពេលបត់ទៅទិសអគ្នេយ៍ឆ្ពោះទៅវត្តច្រកស្តេច។ ប៉ុន្តែ ព្រៃរូងខ្លាមានចម្ងាយឆ្ងាយណាស់នៅទិសពាយ័ព្យពីទីតាំងចេញដំណើររបស់ សំ សិទ្ធី នៅភូមិផ្អេរ វាផ្ទុយទាំងស្រុងទៅនឹងទិសដៅដែលគាត់អះអាងថាបានធ្វើដំណើរទៅ។ ព្រៃរូងខ្លានៅឆ្ងាយពីវត្តច្រកស្តេចដែលធ្វើឲ្យសក្ខីកម្មរបស់ សំ សិទ្ធី មិនទទួលយកបានតាមសភាពជាក់ស្តែងផង ហើយក៏ពុំមានអ្វីមកបញ្ជាក់ពីអត្ថិភាពរបស់វាទាល់តែសោះ។

## ច. សាច់រឿងរបស់ សំ សិទ្ធី មិនសមហេតុផល

[42] ឯកសារ **E3/1714** "បទសម្ភាសន៍ជាមួយជនភៀសខ្លួនកម្ពុជានៅព្រំដែនកម្ពុជា-ថៃ" ខែ កុម្ភៈ - ខែ មីនា ឆ្នាំ ១៩៨០ លេខ ERN 00324749។

[43] ឯកសារ **E3/2763** "បញ្ជីរណ្តៅសាកសព" ('List of burial sites') ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០០៨ លេខ ERN 00379099 (ភាសាអង់គ្លេស) លេខរៀង ១១៥។

21. មានទំនាក់ទំនងរួមតែមួយគត់ដែលភ្ជាប់សក្ខីកម្មផ្សេងៗទាំងនេះអំពីសាច់រឿងរបស់ សំ សិទ្ធី គឺៈ ភាពក្លាហាន វីរភាព និងគំនិតប្រុងប្រយ័ត្នរបស់គាត់ នៅអាយុ១៤ឆ្នាំ ការពិតគឺ*ភាពសំខាន់*ជាទូទៅរបស់គាត់ ក្នុងចំណោមប្រជាជនរាប់ពាន់នាក់ ដែលគាត់អះអាងថាបានប្រមូលផ្តុំគ្នានៅវត្តច្រកស្តេច។ សំ សិទ្ធី ម្នាក់ឯងមានភាពក្លាហានរហូតហ៊ានទៅតាមឪពុកគាត់ទៅក្នុងព្រៃ បន្ទាប់មកវិលត្រឡប់មកអូរវិញ ដើម្បីប្រឹងប្រែងជួយម្តាយ ប្អូនៗ មីង និង (អាច) មាគាត់ទៀតផង។ សំ សិទ្ធី ម្នាក់ឯងមានភាពវាងវៃរហូតពុតធ្វើជាស្លាប់នៅព្រៃរូងខ្លា ដើម្បីបានរស់រានមានជីវិតយ៉ាងអស្ចារ្យជាមួយប្អូនស្រី និងប្អូនជីដូនពីរនាក់។ សំ សិទ្ធី ម្នាក់ឯងចេះប្រើ "យុទ្ធវិធីយោធា" ដើម្បីគេចចេញពីរណ្តៅគ្រាប់ បេ-៥២ ហើយនាំប្អូនស្រី និងប្អូនជីដូនពីរនាក់ត្រឡប់ទៅវត្តវិញ។ ច្បាស់ណាស់គឺ សំ សិទ្ធី និងសាច់ញាតិរបស់គាត់បីនាក់ទៀតគឺជាអ្នកនៅរស់រានតែបួននាក់គត់ មិនមែនត្រឹមតែក្នុងចំណោម ៧ គ្រួសារដែលគាត់អមដំណើរទៅព្រៃរូងខ្លាប៉ុណ្ណោះទេ តែក្នុងចំណោមជនរងគ្រោះសក្តានុពលរាប់ពាន់នាក់ដែលបានប្រមូលផ្តុំគ្នានៅវត្តច្រកស្តេច។ ការពិត សំ សិទ្ធី បានវិលត្រឡប់ទៅវត្តច្រកស្តេចវិញ និងកលល្បិចដ៏វៃឆ្លាតរបស់គាត់ក្នុងពេលដែលកងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជាតាមប្រមាញ់ ដែលបានឲ្យមានការជ្រួលច្របល់តែម្នាក់ឯង ដែលធ្វើឲ្យប្រជាជន "រាប់ពាន់នាក់" ចេញពីវត្តនោះ ក្រោយពេល (ទំនងជា) រង់ចាំនៅទីនោះជាច្រើនថ្ងៃមកហើយ។ បើតាមសំដី សំ សិទ្ធី គឺ សំ សិទ្ធី ខ្លួនឯងគឺជាវីរបុរសដែលមានភាពក្លាហានបំផុត។

22. ការប្រឹងប្រែងរបស់ សំ សិទ្ធី ក្នុងការព្យាយាមធ្វើយ៉ាងណាឲ្យគេជឿជាក់លើរឿងរ៉ាវរបស់ខ្លួនបានត្រឹមតែបង្ហាញនូវភាពសង្ស័យទាំងស្រុងទៅវិញនោះទេ។ សំ សិទ្ធី អះអាងថា ការរត់រួចដ៏កម្ររបស់គាត់ពីរណ្តៅគ្រាប់ បេ-៥២ គឺដោយសារកងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជាបានប្រញាប់ប្រញាលពេកក្នុងពេលកាប់សម្លាប់ពីព្រោះ "មេឃរៀបភ្លៀង"[44]។ យោងតាមសំដីរបស់ សំ សិទ្ធី កងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជាចំនួន ៦ នាក់ ប្រដាប់ដោយកាំភ្លើងអាកា៤៧ និងយល់ច្បាស់អំពីគោលនយោបាយ ប.ក.ក ក្នុងការ "កម្ទេចខ្មាំង" សូម្បីតែដោយសារកំហុសតូចតាចបន្តិចក៏ដោយក្តី ពុំបានអនុវត្តតាមបញ្ជាឲ្យកាប់សម្លាប់ខ្មាំងសំខាន់ៗរបស់បក្សនោះទេពីព្រោះតែពួកគេខ្លាចមេឃរៀបភ្លៀង។ អ្វីដែលមិនគួរឲ្យភ្ញាក់ផ្អើល សំ សិទ្ធី ខ្លួនឯងពុំចងចាំដំណើរដើមទងនៃហេតុការណ៍ដ៏អស្ចារ្យនេះក្នុងរយៈពេលមួយម៉ោងដំបូងក្នុងពេលគាត់ផ្តល់សក្ខីកម្ម។ គាត់បានលើកឡើងថា "មេឃពេលនោះកំពុងភ្លៀង" នៅពេលដែលការកាប់សម្លាប់

---

[44] ប្រតិចារឹកនៃសក្ខីកម្មរបស់ សំ សិទ្ធី ទំព័រ ២៩, ៤២, ១១៧។

បានកើតឡើង[45]។ ទាល់តែក្រោយមកទើបគាត់បានសម្រេចនិយាយថា មេឃភ្លៀងខ្លាំងនោះហើយ ទើបបានបណ្តាលឲ្យកងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជា ចាកចេញទៅបាត់[46]។

23. ការពន្យល់របស់ សំ សិទ្ធី អំពីវិធីដែលគាត់រួចជីវិតពីការកាប់សម្លាប់ដែលគាត់បានអះអាងនោះពុំអាចឲ្យជឿជាក់បានឡើយ។ សំ សិទ្ធី បានផ្តល់សក្ខីកម្មថា ស្ត្រី និងកុមារប្រហែលជា ៣០ នាក់[47] ស្ថិតនៅក្នុងរណ្តៅគ្រាប់ បេ-៥២ ព័ទ្ធជុំវិញដោយកងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជាប្រមាណ ៥ ឬ ៦ នាក់ ដែលប្រដាប់ដោយអាវុធអាកា៤៧។ សំ សិទ្ធី អះអាងថា ទោះបីជាកងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជាទាំង ៥ ឬ ៦ នាក់នោះបានបាញ់ពុំ តម្រង់នៅកៀកៗនឹងអ្នកទាំង ៣០ នាក់នោះនៅក្នុងរណ្តៅតូចមួយក៏ដោយ ក៏ពួកគេបានបាញ់ខុសមនុស្សជាច្រើន ជាហេតុបង្ខំឲ្យពួកគេព្យាយាមយកព្រនុងសំពងអ្នកដែលនៅរស់ត្រង់ក្បាលដើម្បីសម្លាប់ពួកគេចោល។ សំ សិទ្ធី ដែលជាក្មេងជំទង់វ័យ ១៤ ឆ្នាំនៅពេលនោះបានគេចផុតពីការបាញ់រះកៀកដោយគ្រាន់តែអង្គុយលាក់ខ្លួននៅពីក្រោយម្តាយរបស់គាត់[48]។

24. អ្វីដែលចម្លែកបំផុតអំពីសក្ខីកម្មរបស់ សំ សិទ្ធី នោះអាចថា ទោះបីជាគេចាប់ឃាត់នៅវត្តច្រកស្តេចជាមួយនឹងមនុស្ស "រាប់ពាន់នាក់" រួមទាំងសាច់ញាតិ និងអ្នកស្គាល់ឪពុកម្តាយរបស់គាត់ ហើយទោះបីជាបានធ្វើដំណើរពីវត្តច្រកស្តេចទៅព្រៃរូងខ្លាជាមួយនឹងគ្រួសារចំនួន ៧ គ្រួសារ រួមទាំង ពូបងប្អូនជីដូនមួយ និងសាច់ញាតិផ្សេងទៀតក៏ដោយក្តី ក៏ សំ សិទ្ធី មិនអាចប្រាប់ឈ្មោះ សូម្បីបុគ្គលមួយរូបដែលត្រូវបានកងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជាបានសម្លាប់ ព្រមទាំងបុគ្គលណាម្នាក់ក្នុងចំណោមគ្រួសារទាំង ៧ គ្រួសារដែលត្រូវបានគេឃុំនៅវត្តច្រកស្តេច។ ជាការពិតណាស់ សំ សិទ្ធី អះអាងថាចាំមុខនាទីរបស់បុរសពីររូបនៅក្នុងក្រុមនៅវត្តច្រកស្តេចនេះ ប៉ុន្តែគាត់មិនអាចប្រាប់ឈ្មោះពួកគេបាន[49]។ វាមានតម្លៃត្រូវដកស្រង់ទាំងស្រុងតែម្តងនូវវគ្គសួរឆ្លើយពាក់ព័ន្ធនានាដែលក្រុមមេធាវីការពារក្តីទាំងពីរក្រុម និងប្រធានបានព្យាយាមទាញយកព័ត៌មាននេះ

---

[45] *ដូចខាងលើ* ទំព័រ ១៦។

[46] *ដូចខាងលើ* ទំព័រ ២៩, ៤២, ១១៧។

[47] សាក្សីបានលើកឡើងថា មានគ្រួសារចំនួន ៧ គ្រួសារ ដោយគ្រួសារនីមួយៗមានសមាជិកពី ៥ ទៅ ១២ នាក់ ហើយប្រុសៗពេញវ័យចំនួន ១២ នាក់ក្នុងចំណោមគ្រួសារទាំង ៧ គ្រួសារនោះត្រូវបានគេបំបែកចេញទៅមុននៅមុនពេលហេតុការណ៍ដែលគាត់បានរួចជីវិតពីក្នុងរណ្តៅគ្រាប់បេ៥២នោះ។

[48] *ដូចខាងលើ* ទំព័រ ២៨។

[49] *ដូចខាងលើ* ទំព័រ ២២-២៤។

ប៉ុន្តែពុំទទួលបានផ្លែផ្កា៖

សៈ ខ្ញុំសូមសួរលោកអំពីអ្នកដែលនៅរស់ពីព្រោះខ្ញុំបានពិនិត្យមើលមួយភ្លែតនៅក្នុងកុំព្យូទ័ររបស់ខ្ញុំ គ្មាននរណាធ្លាប់បាននិយាយអំពីវត្តច្រកស្ដេចដើម្បីពិពណ៌នាហេតុការណ៍ដែលលោកលើកឡើង នេះទេ គ្មាននរណាម្នាក់នៅក្នុងសំណុំរឿងនេះឡើយ។ លោកបាននិយាយថា មានមនុស្សរាប់ពាន់នាក់ ហើយមានមនុស្សដែលលោកស្គាល់ច្បាស់ ហើយលោកបានរត់មកវត្តនេះវិញជួបជាមួយនឹងអ្នកដែលស្និទ្ធនឹងលោក។ ហើយក្រៅពីជីដូនមួយរបស់លោក ដែលលោកបានប្រាប់យើងទាំងអស់គ្នានោះ តើលោកលោកអាចប្រាប់ឈ្មោះអ្នកផ្សេងដែលនៅរស់ទល់សព្វថ្ងៃទេ ឬ ផ្ដល់ព័ត៌មានដែលជួយឲ្យយើងកំណត់អត្តសញ្ញាណមនុស្សផ្សេងទៀតដែលអាចនៅក្នុងវត្តនោះនៅពេលនោះ ហើយដែលអាចរស់មកទល់សព្វថ្ងៃ?

ឆៈ បាន ខ្ញុំអាចប្រាប់បាន។ ប៉ុន្តែ ខ្ញុំមិនអាចបង្ខំពួកគេឲ្យមកចូលខ្លួននៅចំពោះមុខអង្គជំនុំជម្រះនេះបានទេ ហើយវាជាការល្អលោកស្រីគួរទៅជួបពួកគេនៅតាមផ្ទះរបស់ពួកគេតែម្ដងទៅ។ អ្នកទាំងនេះមួយចំនួនជាសាច់ញាតិឪពុកម្ដាយខ្ញុំ។ ក្រោយខ្ញុំបានជួបពួកគេ ពួកគេបានសួរណាំខ្ញុំថាឪពុកម្ដាយខ្ញុំរស់នៅទីណា។

ប្រធាន៖

លោកសាក្សី សូមលោកឆ្លើយឲ្យខ្លី និងចំចំណុច។ ចម្លើយវែងៗរបស់លោកនាំឲ្យខាតបង់ពេលវេលា។ គ្រាន់តែប្រាប់ខ្លីៗមកថាតើនរណាគេខ្លះទៀតដែលនៅរស់ទល់សព្វថ្ងៃ។

លោក សំ សិទ្ធី៖

ឆៈ សាច់ញាតិខ្ញុំខ្លះនៅរស់នៅទល់សព្វថ្ងៃ។

លោក VERCKEN

សៈ តើលោកអាចប្រាប់ឈ្មោះខ្លះបានទេ?

លោក សំ សិទ្ធិ

ឆៈ ខ្ញុំមិនអាចប្រាប់នៅពេលនេះបានទេដោយសារខ្ញុំមិនស្គាល់ឈ្មោះពិតរបស់ពួកគេផងនោះ[50]។

25. ជាជាងស្នើសុំឲ្យកែសម្រួលសក្ខីកម្មរបស់ សំ សិទ្ធី ប្រហែលតាមរយៈការស្នើសុំឲ្យបង្ហាញព័ត៌មានលម្អិតដែលស៊ីសង្វាក់នឹងគ្នា សហព្រះរាជអាជ្ញាបានត្រឹមតែយោងលើហេតុការណ៍ទាំងនេះនៅក្នុង

[50] *ដូចខាងលើ* ទំព័រ ១១៨-១២០។ *សូមមើលផងដែរ* ទំព័រ ២២ (សាក្សីព្រមប្រាប់ថា គាត់មិនអាចចងចាំឈ្មោះអ្នកទាំងឡាយដែលស្ថិតនៅក្នុងចំណោមគ្រួសារទាំង ៧ គ្រួសារដែលត្រូវបានគេនាំមកព្រៃរូងខ្លានោះទេ។

អំឡុងពេលសួរសាក្សីរូបនេះតែប៉ុណ្ណោះ។ ផ្ទុយមកវិញ សហព្រះរាជអាជ្ញាបានផ្តោតលើការសួរសំណួរស្ទើរតែទាំងស្រុងលើបញ្ហានៃភាពពុំជាប់ទាក់ទងនឹងបណ្តឹងសាទុក្ខទៅវិញ ឬ នៅក្នុងករណីខ្លះ លើសំណុំរឿង ០០២ ទាំងមូល[51]។ សហព្រះរាជអាជ្ញាបានបន្តប្រើប្រាស់វិធីសាស្ត្រនេះសួរសំណួរទៅកាន់សាក្សី បើទោះជាមានការជំទាស់ជាច្រើនលើកច្រើនសារពីក្រុមមេធាវីការពារក្តីក៏ដោយ[52]។ វិធីសាស្ត្រនេះអាចជួយបាននៅពេលនោះ ពីព្រោះក្នុងពេលបង្ហាញខ្លួនក្នុងរយៈពេលខ្លីបែបនេះនៅចំពោះមុខអង្គជំនុំជម្រះ សំ សិទ្ធី អាចគេចវៀសមិនជាន់កែងខ្លួនឯងបាន។ សម្រាប់សហព្រះរាជអាជ្ញា ការយកចិត្តទុកដាក់លើរឿងនិទានរបស់ សំ សិទ្ធី កាន់តែតិចកាលណា កាន់តែល្អកាលហ្នឹង។

## III. ឧបត្ថម្ភករណ៍

26. ដូចមានការបង្ហាញនៅក្នុងបណ្តឹងសាទុក្ខ សក្ខីកម្មសាក្សីផ្ទាល់ភ្នែកមួយចំនួនតូចប៉ុណ្ណោះដែលបង្ហាញអំពីជោគវាសនារបស់អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ឬនៅក្នុងអំឡុងថ្ងៃនោះ ឃើញមាននៅក្នុងទម្រង់ផ្សេងៗនៅក្នុងសំណុំរឿង។ បុគ្គលតែម្នាក់គត់ដែលបានផ្តល់សក្ខីកម្មបែបនេះនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងគឺ គឹម វ៉ាន់ឌី។ ភ័ស្តុតាងរបស់បុគ្គលរូបនេះជាប់ទាក់ទងនឹងការស្លាប់ពូរបស់ខ្លួន នៅមុនពេលការប្រយុទ្ធគ្នាបានបញ្ចប់[53] យោងតាមការអះអាងរបស់សហព្រះរាជអាជ្ញា[54]។ ការរៀបរាប់ជាច្រើនទៀតនៅក្នុងសំណុំរឿង - ជាការពិត មិនមែនតែនៅក្នុងសំណុំរឿងប៉ុណ្ណោះទេ ប៉ុន្តែនៅក្នុងចំណោមការជ្រើសរើសតាមទំនើងចិត្តពីឯកសារចំនួនប្រហែល ១០ ទៅ ២០ ដែលត្រូវបានដកស្រង់នៅក្នុងសាលក្រមក្នុងគោលបំណងជាក់លាក់ដើម្បីបង្ហាញថាទាហាននៃរបបសាធារណរដ្ឋខ្មែរត្រូវបានសម្លាប់ចោល - បង្ហាញថា ទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរដែលត្រូវបានចាប់ខ្លួនក្នុងរយៈពេលប៉ុន្មានថ្ងៃក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ត្រូវបានបញ្ជូនទៅមន្ទីរឃុំឃាំងអស់រយៈពេលមួយ

---

[51] *សូមមើលឧទាហរណ៍ ដូចខាងលើ* ទំព័រ ៧៦-៧៩, ៨១-៨២។

[52] *ដូចខាងលើ* ទំព័រ ៧៩-៨០, ៩៣, ៩៩, ១០១, ១០៥។

[53] ឯកសារ **E1/148.1** "ប្រតិចារឹកនៃកិច្ចដំណើរការនីតិជំនុំជម្រះនៅក្នុងសំណុំរឿង ០០២" (គឹម វ៉ាន់ឌី) ថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០១២ ទំព័រ ៨៣:១១-១៨។ បណ្តឹងសាទុក្ខ កថាខណ្ឌ ៥៩៣។

[54] ឯកសារ **F17/1** "ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១" ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៥ ("ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខ") កថាខណ្ឌ ១៦៥។

រយៈពេលខ្លី មុនពេលដោះលែងឱ្យទៅនៅតាមសហករណ៍នានា[55]។ ដូច្នេះ សំ សិទ្ធី គឺជាបុគ្គលតែម្នាក់គត់ ពោលគឺ គាត់គឺជាមនុស្សតែម្នាក់គត់ដែលបានរៀបរាប់រឿងរ៉ាវដែលគាត់ជួបប្រទះផ្ទាល់នៅចំពោះមុខចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះនៃសាលាក្តីនេះដោយបានបញ្ជាក់ថា ទាហាននៃរបបសាធារណរដ្ឋខ្មែរដែលត្រូវបានចាប់ខ្លួន និងដកចេញនៅក្នុងអំឡុងពេលជម្លៀសពីទីក្រុងត្រូវបានសម្លាប់ចោលនាពេលក្រោយមក។ ជាការពិតណាស់ ការរៀបរាប់របស់ សំ សិទ្ធី មានតែមួយគត់នៅក្នុងសំណុំរឿងក្នុងទម្រង់នានា ដូចជា - ពាក្យចចាមអារ៉ាម ឬ បើមិនដូច្នោះទេ រួមទាំងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងជនអនាមិកនៃចម្លើយដែលបានទទួលនៅក្រៅក្របខ័ណ្ឌតុលាការការ - ដែលទំនងពិពណ៌នាអំពីការសម្លាប់គ្រួសារអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរកើតឡើងតាំងពីរយៈពេលយូរ មុនពេលរំដោះប្រទេសទៅទៀត។

27. បណ្តឹងសាទុក្ខនេះបានបង្ហាញបន្ថែមទៀតថា បទដ្ឋានអន្តរជាតិទាមទារឱ្យអង្គជំនុំជម្រះសាលាដំបូងវាយតម្លៃលើអង្គហេតុនានាដែលបានស្តែងឱ្យឃើញតាមរយៈសក្ខីកម្មផ្ទាល់ជាមុនសិន មុននឹងឈានទៅពិចារណាថាតើចម្លើយដែលទទួលបាននៅក្រៅក្របខ័ណ្ឌតុលាការ ស៊ីសង្វាក់គ្នានឹងសក្ខីកម្មដែលបានស្តាប់នៅចំពោះមុខអង្គជំនុំជម្រះដែរឬទេ[56]។ ជាពិសេស អង្គជំនុំជម្រះសាលា

[55] *សូមមើលឧទាហរណ៍* ឯកសារ **E3/5397** "ទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះ ម៉ី ណារី" ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៨ ERN 00834021 (ពិពណ៌នាថាត្រូវបានគេជម្លៀសទៅ "កន្លែងការដ្ឋានក្រុមអ្នករដ្ឋការចាស់")។ *សូមមើលឧទាហរណ៍* ឯកសារ **E3/4822** "ទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះ អ៊ឹម គ្រេះ" ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០០៨ ERN 00893354 (ទាហាននៃរបបសាធារណរដ្ឋខ្មែរត្រូវបានគេបញ្ជូនទៅអប់រំរួមជាមួយនឹងទាហានចំនួន ៥០០ នាក់ផ្សេងទៀត)។ ឯកសារ **E3/5232** "កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គង់ សំអាត" ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០០៨ ERN 00279257 (ទាហាននៃរបបសាធារណរដ្ឋខ្មែរដែលត្រូវបានគេបំបែកចេញពីក្រុមត្រូវបាននាំយកទៅរស់នៅតាមសហករណ៍ផ្សេងៗពីគ្នា)។ ឯកសារ **E3/5232** "កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដុច ពន្លក" ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០០៩ ERN 00275399 (ទាហាននៃរបបសាធារណរដ្ឋខ្មែរដែលត្រូវបានគេប្រមូលផ្តុំឱ្យនៅម្តុំក្រោយការប្រកាសរបស់កងទ័ពប្រជាជនរំដោះជាតិកម្ពុជាត្រូវបាននាំយកទៅធ្វើស្រែ)។ ឯកសារ **E3/5598** "មជ្ឈមណ្ឌលឯកសារកម្ពុជា កិច្ចសម្ភាសន៍ជាមួយនឹង ខាត់ ជិន" ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៥ ERN 00874736 (ទាហានដែលបានចុះចាញ់ និងដោះសម្លៀកបំពាក់ចេញនោះ "ត្រូវបានទុកឱ្យរួចផុតពីសេចក្តីស្លាប់" ហើយ "ពុំត្រូវបានគេបញ្ជូនចេញទៅនោះទេ")។ ឯកសារ **E3/1593** "របបប៉ុលពត៖ ពូជសាសន៍ អំណាច អំពើប្រល័យពូជសាសន៍" ERN 00678599 (ពិពណ៌នាថា ទាហាន និងអ្នករដ្ឋការជិត ១,០០០ នាក់ត្រូវបានគេបញ្ជូនទៅអប់រំនៅក្នុងខែ មេសា ឆ្នាំ ១៩៧៥ ហើយត្រូវបានគេដោះលែងមកវិញប៉ុន្មានខែក្រោយមក")។ *សូមមើលផងដែរ* បណ្តឹងសាទុក្ខ កថាខណ្ឌ ៥៨៥, ៥៩០។ ឯកសារ **E295/6/3** "សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលនៅក្នុងសំណុំរឿង ០០២/០១" ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ កថាខណ្ឌ ៣៨៤។

[56] បណ្តឹងសាទុក្ខ កថាខណ្ឌ ១៦១។

ដំបូងគួរប្រុងប្រយ័ត្នជាពិសេស នៅក្នុងការវាយតម្លៃលើចម្លើយដែលទទួលបាននៅក្រៅក្របខ័ណ្ឌតុលាការដែលការិយាល័យសហព្រះរាជអាជ្ញាយកមកសំអាងដើម្បីបង្ហាញនូវបែបផែនទ្រង់ទ្រាយធំនៃទង្វើក្នុងគោលបំណងធ្វើជាមធ្យោបាយមួយ ក្នុងការបង្ហាញការទទួលខុសត្រូវព្រហ្មទណ្ឌរបស់បុគ្គល[57]។ ស្រដៀងគ្នានេះដែរ អង្គជំនុំជម្រះសាលាដំបូងគួរពិចារណាដកចេញចម្លើយដែលបានទទួលនៅក្រៅក្របខ័ណ្ឌតុលាការដែលជាប់ទាក់ទងនឹង "បញ្ហាថ្មីៗ" រវាងភាគី និងដើម្បីផ្តល់ទម្ងន់តិចតួចលើចម្លើយបែបនេះដែលត្រូវបានទទួលយកមកដាក់បញ្ចូលជាភ័ស្តុតាង[58]។ សូម្បីបទដ្ឋានទាំងនេះក៏ពុំគ្រប់គ្រាន់នៅក្នុងកិច្ចដំណើរការនីតិវិធីទាំងនេះផងដែរ ពីព្រោះខុសពីសាលាក្តី *មិនអចិន្ត្រៃយ៍*នានាដែលបទដ្ឋានទាំងនេះមានដើមកំណើតចេញមក ក្រុមមេធាវីការពារក្តី មិនត្រូវបានអនុញ្ញាតទាំងស្រុងឲ្យចូលរួមនៅក្នុងដំណើរការស៊ើបអង្កេត ខណៈតួនាទីរួមនេះត្រូវបានប្រគល់ឲ្យទៅសហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី[59]។ ជាងនេះទៀត អង្គជំនុំជម្រះគួរពិចារណាជាពិសេសលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងបណ្តឹងរបស់ជនរងគ្រោះដែលត្រូវបានរៀបចំឡើងក្នុងគោលបំណងធ្វើជាបណ្តឹង ដោយពុំបានស៊ើបសួរដោយមន្ត្រីតុលាការ ឬភាគីនៃកិច្ចដំណើរការនីតិវិធី ក្រៅតែពីដើមបណ្តឹងរដ្ឋប្បវេណីខ្លួនឯង[60]។ ឯកសារទាំងនោះទំនងជាត្រូវបានដកចេញទាំងស្រុងតែម្តងពីការជំនុំជម្រះ នៅតាមបណ្តាសាលាក្តី *មិនអចិន្ត្រៃយ៍*នានា ហើយដោយសារលក្ខខណ្ឌដាច់ខាត ហាមឃាត់ នួន ជា មិនឲ្យប្រមូលភ័ស្តុតាងដោះបន្ទុកទៀតនោះ ការសំអាងទាំងស្រុងដោយអង្គជំនុំជម្រះសាលាដំបូងលើឯកសារទាំងនេះក្នុងគោលបំណងសំខាន់ៗនោះគឺជាការរំលោភជាក់ស្តែងលើសមភាពរវាងគូភាគីក្តី។ យោងតាមការវិភាគផ្ទាល់របស់អង្គជំនុំជម្រះសាលាដំបូង ឯកសារទាំងនេះមានលទ្ធភាពទទួលបាន "ទម្ងន់តិចតួចប៉ុណ្ណោះ ប្រសិនបើមាននោះ"[61]។

28. នៅក្នុងករណីនេះ ការអនុវត្តបទដ្ឋានទាំងនេះទាមទារឲ្យយកសក្ខីកម្មរបស់ សំ សិទ្ធី មកពិនិត្យពិច័យឲ្យបានល្អិតល្អន់បំផុត ប្រសិនបើអាចធ្វើបាន។ សហព្រះរាជអាជ្ញាទទូចឡើងថា លក្ខខណ្ឌរីករាលដាលនៃការសម្លាប់ដូចបានអះអាងថាបានកើតឡើងនៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ឬ

---

[57] បណ្តឹងសាទុក្ខ កថាខណ្ឌ ១៦២។

[58] បណ្តឹងសាទុក្ខ កថាខណ្ឌ ១៦២។

[59] បណ្តឹងសាទុក្ខ កថាខណ្ឌ ៣១-៣២, ១៣៣-១៣៤។

[60] បណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៦, ១៦៥។

[61] បណ្តឹងសាទុក្ខ កថាខណ្ឌ ១៦៥។

ក៏ប្រហែលជាអំឡុងថ្ងៃនោះមានសារៈសំខាន់ ក្នុងការបង្ហាញនូវអត្ថិភាពនៃគោលនយោបាយសហឧក្រិដ្ឋកម្មរួមក្នុងការកំណត់គោលដៅលើទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ[62]។ នួន ជា ជំទាស់ដាច់អហង្កាចំពោះការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ការសម្លាប់ទាំងនេះត្រូវបានប្រព្រឹត្ត។ ជំហរជំទាស់នេះគាំទ្រដោយភ័ស្តុតាងជាច្រើនដែលអង្គជំនុំជម្រះសាលាដំបូងបានដកស្រង់ដោយខ្លួនឯងនៅក្នុងសាលក្រម[63]។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី បណ្តឹងជនរងគ្រោះ និងចម្លើយផ្សេងៗទៀតដែលទទួលបាននៅក្រៅក្របខ័ណ្ឌតុលាការដែលពុំមានយថភាព គឺជាបណ្តុំនៃភ័ស្តុតាងដែលបានដកស្រង់នៅក្នុងសាល-ក្រម។ ផ្អែកតាមកាលៈទេសៈទាំងនេះ ការវាយតម្លៃដ៏ប្រយ័ត្នប្រយែងមួយលើសក្ខីកម្មរបស់ សំ សិទ្ធី រួមទាំងគុណភាពនៃភ័ស្តុតាងស៊ីសង្វាក់គ្នា គឺជាគ្រឹះសំខាន់មួយដែលការវាយតម្លៃលើភ័ស្តុតាងដោយអង្គជំនុំជម្រះនេះចំពោះភ័ស្តុតាង (ជារឿយៗ ភ័ស្តុតាងដោះបន្ទុក) ដូចបានដកស្រង់នៅក្នុងសាលក្រម ចាំបាច់ត្រូវយកមកសំអាង[64]។

29. ដោយសារផលវិបាកនៃការមិនអនុញ្ញាតឲ្យក្រុមមេធាវីការពារក្តីចូលរួមនៅគ្រប់ដំណាក់កាលទាំងអស់នៃការស៊ើបអង្កេត ទើបក្រុមមេធាវីការពារក្តីពុំមានលទ្ធភាពប្រឹងប្រែងជាមុនក្នុងការជំទាស់ ឬផ្ទៀងផ្ទាត់ខ្លឹមសារនៃសក្ខីកម្មរបស់ សំ សិទ្ធី។ ដោយសារមូលហេតុនេះ ក្រុមមេធាវីការពារក្តីបានដាក់សំណើម្តងហើយម្តងទៀតជូនសហចៅក្រមស៊ើបអង្កេត ដើម្បីស្នើសុំបំពេញកិច្ចស៊ើបសួរ

---

[62] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខ កថាខណ្ឌ ៥១។

[63] *សូមមើល* កថាខណ្ឌ ២៦ ខាងលើ។

[64] ដូចបណ្តឹងសាទុក្ខបានតវ៉ា វាមានហេតុផលជាច្រើនដែលសមស្របនឹងធ្វើការពិនិត្យភ័ស្តុតាងនេះ*សារជាថ្មី*។ ចំណុចទីមួយ អង្គជំនុំជម្រះនេះមានយុត្តាធិការក្នុងនាមជាតុលាការកំពូលនៅក្នុងប្រព័ន្ធតុលាការជាតិកម្ពុជា។ *សូមមើល*បណ្តឹងសាទុក្ខ កថាខណ្ឌ ២-១១។ ចំណុចទីពីរ អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសគួរយកមកពិចារណានៅក្នុងការវិភាគរបស់ខ្លួនអំពីគោលនយោបាយកំណត់គោលដៅនៃសហឧក្រិដ្ឋកម្មរួម។ កំហុសទាំងនេះមានលក្ខណៈធ្ងន់ធ្ងរនៅក្នុងការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងលើការប្រព្រឹត្តលើទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅមុនឆ្នាំ ១៩៧៥ ហើយនឹងការណែនាំរបស់មជ្ឈិមបក្សលើបញ្ហានេះក្រោយពេលរំដោះ រួមទាំងការបង្ហាញមិនត្រឹមត្រូវជាហូរហែរបស់អង្គជំនុំជម្រះសាលាដំបូងលើភ័ស្តុតាង និងការខកខានជាលក្ខណៈប្រព័ន្ធរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការទទួលស្គាល់ភ័ស្តុតាងដោះបន្ទុកពីប្រភពនានាដែលអង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញម្តងហើយម្តងទៀតថាអាចទុកចិត្តបាន។ *សូមមើល*បណ្តឹងសាទុក្ខ កថាខណ្ឌ ៥២៩-៥៧៣ (ដកស្រង់ឯកសារសំអាងពាក់ព័ន្ធ)។ ទោះក្នុងករណីណាក៏ដោយ កត្តាទាំងឡាយដូចបានបង្ហាញនៅទីនេះគឺជាចំណុចស្នូលទៅនឹងការវាយតម្លៃរបស់អង្គជំនុំជម្រះនេះលើសំអាងហេតុនៅក្នុងសាលក្រមស្តីពីបទដ្ឋាននៃការពិនិត្យមើលឡើងវិញ។

ដោយក្នុងនោះបានស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតប្រឹងប្រែងខ្លាំងក្លាជាងនេះក្នុងការវាយតម្លៃលើភាពអាចទុកចិត្តបាននៃសក្ខីកម្មសាក្សី និងដើម្បីទទួលបានភស្តុតាងដែលស៊ីសង្វាក់គ្នា[65]។ នៅក្នុងអំឡុងពេលជំនុំជម្រះ ក្រុមមេធាវីការពារក្តីស្នើសុំឱ្យ សំ សិទ្ធី ចូលខ្លួនមកផ្តល់សក្ខីកម្ម ប៉ុន្តែអង្គជំនុំជម្រះសាលាដំបូងបានជំទាស់[66]។ ដូច្នេះ វាគ្មានវេទិកាស្នើសុំឱ្យមានដំណោះស្រាយណាមួយអាចធ្វើឡើងទៅបាននាពេលនោះឡើយ។

30. ដូចអង្គជំនុំជម្រះនេះធ្លាប់បានសម្រេចនាពេលថ្មីៗនេះរួចហើយ វិធាន ១០៤(១)នៃវិធានផ្ទៃក្នុងផ្តល់ឆន្ទានុសិទ្ធិធំធេងដល់អង្គជំនុំជម្រះនេះក្នុងការកោះហៅភស្តុតាងថ្មីណាមួយដែលខ្លួនយល់ឃើញថាដើម្បីជាផលប្រយោជន៍នៃយុត្តិធម៌[67]។ ការសម្រេចនេះរួមបញ្ចូលទាំងការវាយតម្លៃថាតើភស្តុតាងនានាមានប្រយោជន៍ដល់ការបញ្ជាក់ការពិតដែរឬទេ។ ដោយយល់ឃើញនូវសារៈសំខាន់នៃសក្ខីកម្មរបស់ សំ សិទ្ធី ក្នុងបរិបទនៃភស្តុតាងដូចបានដកស្រង់នៅក្នុងសាលក្រម ព្រមទាំងចំណុចផ្ទុយគ្នាជាច្រើននៅក្នុងសក្ខីកម្មរបស់គាត់ និងនត្ថិភាពនៃភស្តុតាងដែលស៊ីសង្វាក់គ្នានៅក្នុងសំណុំរឿងនោះ កិច្ចស៊ើបសួរដូចបានលើកឡើងនៅក្នុងកថាខណ្ឌ ៣១ ខាងក្រោម បានបំពេញបទដ្ឋាននេះយ៉ាងពិតប្រាកដ។

## IV. សំណើសុំ

31. អាស្រ័យហេតុនេះ ក្រុមមេធាវីការពារក្តីស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូល អនុលោតាមវិធាន ១០៤(១) នៃវិធានផ្ទៃក្នុង បំពេញកិច្ចតែងតាំងអ្នកស៊ើបអង្កេតមួយរូបឱ្យប្រមូលភស្តុតាងផ្ទៀងផ្ទាត់ជាមួយនឹងសក្ខីកម្មរបស់ សំ សិទ្ធី រួមទាំង យ៉ាងហោចណាស់ បំពេញកិច្ចស៊ើបសួរដូចខាងក្រោម៖

(ក) ស្តាប់ចម្លើយបងប្អូនជីដូនមួយស្រីរបស់ សំ សិទ្ធី ឈ្មោះ សំ គឹមសុខ មានអាស័យដ្ឋាន

[65] ឯកសារ **D318** "សំណើទី១៩ ស្នើសុំបំពេញកិច្ចស៊ើបសួរ" ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១០។ ឯកសារ **D319** "សំណើទី១២ ស្នើសុំបំពេញកិច្ចស៊ើបសួរ" ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១០។ ឯកសារ **D320** "សំណើទី២១ ស្នើសុំបំពេញកិច្ចស៊ើបសួរ" ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១០។ ឯកសារ **D336** "សំណើទី២២ ស្នើសុំបំពេញកិច្ចស៊ើបសួរ" ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១០។ ឯកសារ **D338** "សំណើទី២៣ ស្នើសុំបំពេញកិច្ចស៊ើបសួរ" ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ២០១០។ ឯកសារ **D339** "សំណើទី២៤ ស្នើសុំបំពេញកិច្ចស៊ើបសួរ" ចុះថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ ២០១០។ ឯកសារ **D340** "សំណើទី២៥ ស្នើសុំបំពេញកិច្ចស៊ើបសួរ" ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១០។

[66] ឯកសារ **E291/2** "សំណើសុំកោះហៅសាក្សីពាក់ព័ន្ធនឹងការចោទប្រកាន់អំពីគោលនយោបាយនៃការកំណត់មុខសញ្ញាមន្ត្រីសាធារណរដ្ឋខ្មែរ" ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៣។ បណ្តឹងសាទុក្ខ កថាខណ្ឌ ៨៥។

[67] សេចក្តីសម្រេចលើសំណើរបស់ នួន ជា កោះហៅសាក្សី កថាខណ្ឌ ១៧។

នៅក្នុងភូមិទ្រាជើង ឃុំស្រែថ្មី ស្រុករលៀប្អៀ ខេត្តកំពង់ឆ្នាំង។

(ខ) កំណត់ថាតើទីតាំងឈ្មោះព្រៃរូងខ្លាស្ថិតនៅក្នុងរង្វង់ចម្ងាយពីរគីឡូម៉ែត្រពីវត្តច្រកស្តេចដែរ ឬទេ ហើយប្រសិនដូច្នេះមែន ព្យាយាមកំណត់រកផ្នូរសាកសព តាមរយៈភស្តុតាងរូបវត្ថុ និង/ឬ ការសម្ភាសន៍ជាមួយនឹងអ្នកស្រុក។

(គ) សម្ភាសន៍អ្នកស្រុកនៅច្រកស្តេចដើម្បីធ្វើយ៉ាងណាបញ្ជាក់ផ្ទៀងផ្ទាត់លើខ្លឹមសារនៃសក្ខីកម្ម របស់ សំ សិទ្ធី និង

(ឃ) ស្វែងរកអត្តបទសម្ភាសន៍របស់ សំ សិទ្ធី នៅក្នុងកាសែតកោះសន្តិភាព។

បើពុំដូច្នោះទេ មេធាវីការពារក្តីស្នើសុំឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យខ្លួនធ្វើការស៊ើបអង្កេតដោយខ្លួនឯងលើអង្គហេតុទាំងនេះ។

**សហមេធាវីការពារក្តី នួន ជា**

សុន អរុណ Victor KOPPE